# ការបោះបង់ទីលំនៅរបស់អ្នកភូមិតាមដងទន្លេសេសាន

# ក្នុងខេត្តរតនគិរី ភាគឦសាននៃប្រទេសកម្ពុជា









គំរោងសិក្សាស្រាវជ្រាវ

ដោយសហគមន៍

ដោយមានការជួយគាំទ្រផ្នែកបច្ចេកទេស ពី អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង

ខែ សីហា ឆ្នាំ ២០០៧

3 S Rivers Protection Network

បោះពុម្ពដោយ :

**អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង**

ប្រអប់សំបុត្រ : ៨៩០០៧

ស្រុកបានលុង ខេត្តរតនគិរី ប្រទេសកម្ពុជា

ទូរស័ព្ទ : (៨៥៥) ៧៥ ៩៧៤ ១១២

អ៊ីមែល : sesan@camshin.net

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានផ្តួចផ្តើមគំនិតដោយប្រជាជនមូលដ្ឋានដែលរស់នៅតាមដងទន្លេសេសាន ក្នុងខេត្តរតនគិរី ភាគឦសាននៃប្រទេសកម្ពុជា។ ការសិក្សានេះត្រូវបានធ្វើឡើងដោយអ្នកស្រាវជ្រាវមកពីសហគមន៍ចំនួន ១៧នាក់ ដោយមានការគាំទ្របច្ចេកទេសពីអង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង។ ហើយអង្គការប្រូឌឺលីងដេលែន ជាអ្នកឧបត្ថម្ភថវិកាសំរាប់ការបោះពុម្ពរបាយការណ៍។

ឈ្មោះរបាយការណ៍ដែលតំរូវអោយសរសេរក្នុងឯកសារយោង :

អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង ឆ្នាំ ២០០៧។ ***ការបោះបង់លំនៅដ្ឋាននៅតាមដងទន្លេ សេសាន ក្នុងខេត្តរតនគិរី ភាគឦសាននៃប្រទេសកម្ពុជា ៖*** អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង ស្រុកបានលុង ខេត្តរតនគិរី ប្រទេសកម្ពុជា។

# មាតិកា


ខ្លឹមសារសង្ខេប ........ ក

សេចក្តីថ្លែងអំណរគុណ ........ គ

១. សេចក្តីផ្តើម ........ ១

២. គោលដៅ និងគោលបំណងនៃការសិក្សា ........ ២

៣. តំបន់ និងព្រំដែននៃការសិក្សា ........ ២

៤. វិធីសាស្ត្រនៃការសិក្សា ........ ៥

៥. លទ្ធផលនៃការសិក្សា ........ ៦

៥-១ ទិដ្ឋភាពទូទៅនៃការចាកចេញពីទន្លេ ចំនួនប្រជាជនចាកចេញពីទន្លេ និងកំពុងរស់នៅតាមដងទនេ........ ៦

៥-២ មូលហេតុនៃការចាកចេញពីទន្លេ ........ ១៤

៥.២.១ ទឹកជំនន់ញឹកញាប់ ........ ១៤

៥.២.២ ខ្លាចទំនប់បាក់ ........ ១៦

៥.២.៣ បញ្ហាសន្តិសុខស្បៀង ........ ១៨

ក. ទឹកជំនន់បំផ្លាញស្រូវញឹកញាប់ ........ ១៨

ខ. ការបាត់បង់ធនធានទន្លេ ........ ១៩

គ. បាត់បង់ប្រភពប្រាក់ចំណូលតាមគ្រួសារ ........ ១៩

៥.២.៤ ចង់បានចំការថ្មី និងការពារដីកុំអោយអ្នកក្រៅចាប់យក ........ ២០

៥-៣ ឥទ្ធិពលនៃការចាកចេញពីទន្លេ ........ ២០

៥.៣.១ ឥទ្ធិពលវិជ្ជមាន ........ ២០

ក. សន្តិសុខស្បៀង ........ ២០

ខ. ការរកប្រាក់ចំណូល ........ ២២

គ. សុខភាព ........ ២៣

ឃ. មិនខ្លាចទំនប់បាក់ ........ ២៣

៥.៣.២ ឥទ្ធិពលអវិជ្ជមាន ....................................................................... ២៤
ក. បាត់បង់ដីស្រែចំការ ....................................................................... ២៤
ខ. ការអប់រំ ....................................................................... ២៥
គ. ការប្រើប្រាស់ព្រៃឈើសំរាប់ចំការថ្មី ....................................................................... ២៦
ឃ. ខ្វះទឹកប្រើប្រាស់ ....................................................................... ២៧
ង. មធ្យោបាយធ្វើដំណើរ ....................................................................... ២៧
**៦. ការសន្និដ្ឋាន** ....................................................................... ២៩
**៧. អនុសាសន៍** ....................................................................... ៣០

**ឯកសារភ្ជាប់បន្ថែម**

ស្ថិតិប្រជាជនកំពុងរស់នៅតាមដងទន្លេសេសានក្នុងស្រុកអូរយ៉ាដាវ ....................................................................... ៣១
ស្ថិតិប្រជាជនកំពុងរស់នៅតាមដងទន្លេសេសានក្នុងស្រុកអណ្តូងមាស ....................................................................... ៣១
ស្ថិតិប្រជាជនកំពុងរស់នៅតាមដងទន្លេសេសានក្នុងស្រុកតាវែង ....................................................................... ៣១
ស្ថិតិប្រជាជនកំពុងរស់នៅតាមដងទន្លេសេសានក្នុងស្រុកវើនសៃ ....................................................................... ៣២

# ខ្លឹមសារសង្ខេប

ប្រជាជនរាប់ម៉ឺនពាន់នាក់ ជាពិសេសជនជាតិដើមភាគតិចបាន និងកំពុងរស់នៅពឹងអាស្រ័យលើទន្លេសេសានតាំង ពីយូរយាណាស់មកហើយ ប៉ុន្តែទន្លេសេសាននាពេលបច្ចុប្បន្នបានធ្វើអោយពួកគាត់អស់ក្តីសង្ឃឹមកាន់តែខ្លាំងឡើងៗទៅវិញ ។ នេះដោយសារតែទន្លេសេសានត្រូវបានទទួលរងនូវការគំរាមកំហែងយ៉ាងខ្លាំងពីទំនប់វារីអគ្គីសនីនៅតាមតំបន់ខ្សែទឹកខាងលើ ។

ដើម្បីចូលរួមស្រោចស្រង់អាយុជីវិតទន្លេសេសាន ក៏ដូចជាជោគវាសនាខ្លួនឯងផ្ទាល់ ប្រជាជនរងគ្រោះតាមដងទន្លេសេសានបានព្យាយាមពុះពារគ្រប់ឧបសគ្គ និងការលំបាកយ៉ាងច្រើនក្នុងការតស៊ូទាមទារការធ្វើអោយប្រសើរឡើងវិញនូវស្ថានភាពសេដ្ឋកិច្ច សង្គម បរិស្ថាន និងការគោរពសិទ្ធិមនុស្ស ។

ជាក់ស្តែងការផ្តួចផ្តើមគំនិតថ្មីមួយត្រូវបានចាប់ផ្តើមឡើងដើម្បីចូលរួមចំណែកដល់ការការពារទន្លេសេសាននោះ គឺសហគមន៍រងគ្រោះតាមដងទន្លេបានធ្វើការសិក្សាដោយមានការចូលរួមមួយស្តីពី "**ការបោះបង់លំនៅដ្ឋាននៅ តាមដងទន្លេសេសានក្នុងខេត្តរតនគិរី**" ។

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងដោយសហគមន៍មូលដ្ឋានតាមដងទន្លេសេសាន និងមានការជួយ គាំទ្រខាងបច្ចេកទេសក្នុងការអនុវត្តន៏ និងការសរសេររបាយការណ៏ពី **អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង** ហើយការសិក្សានេះចាប់ផ្តើមចាប់តាំងពីខែឧសភា ដល់ខែ តុលា ឆ្នាំ ២០០៦ ដើម្បីប្រមូលព័តិមានទាក់ទង នឹងការបោះបង់ទីលំនៅតាមដងទន្លេសេសាន ។

ក្រុមសិក្សាបានរកឃើញថាមានអ្នកភូមិចំនួន **៧២២** គ្រួសារ ដែលមានចំនួនប្រជាជនសរុប **៣,៩៤៥** នាក់ ក្នុងនោះមានស្ត្រីចំនួន **១,៨00** នាក់ នៅក្នុងភូមិចំនួន **១៧** ឃុំចំនួន ៨ នៃស្រុកទាំង ៤ បានចាកចេញពីទន្លេសេសានទៅរស់នៅតាមតំបន់ខ្ពង់រាប និងតំបន់ភ្នំឆ្ងាយពីទន្លេ ។ អ្នកភូមិដែលបានចាកចេញពីទន្លេសេសានទាំងនោះភាគច្រើនជាជន ជាតិដើមភាគតិច ក្រៅពីនោះមានជនជាតិឡាវប្រមាណ ១0គ្រួសារ ប៉ុណ្ណោះ ។ ហើយនៅបច្ចុប្បន្ននេះមានអ្នកភូមិ ចំនួន **៤,0៧១** គ្រួសារ ដែលមានប្រជាជនសរុបចំនួន **២0,0៣៤** នាក់ ក្នុងនោះមានស្ត្រីចំនួន **១0,២៤៦** នាក់ នៅក្នុងភូមិចំនួន ៥៦ ឃុំចំនួន ១៤ នៃស្រុកទាំង ៤ កំពុងរស់នៅតាមដងទន្លេសេសានក្នុងខេត្តរតនគិរី ។ ប្រជាជនដែលកំពុងរស់នៅតាមដងទន្លេសេសានសព្វថ្ងៃនេះភាគច្រើនជាជនជាតិដើមភាគតិច និងជនជាតិឡាវ ចំណែកឯជនជាតិផ្សេងៗ ទៀតរួមមានជនជាតិចិន និងខ្មែរ ។

យោងតាមការពិភាក្សាជាមួយអ្នកភូមិបានអោយដឹងថា មូលហេតុដែលសំខាន់ជាងគេបំផុតនៃការចាកចេញពី ទន្លេគឺទឹកជំនន់ ។ ទឹកជំនន់ញឹកញាប់តាមដងទន្លេសេសានមិនត្រឹមតែបំផ្លាញទ្រព្យសម្បត្តិ ផលស្រូវ ស្រែចំការ និងសួនដំណាំតាមមាត់ទន្លេប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងធ្វើអោយអ្នកភូមិតាមដងទន្លេមានអារម្មណ៏ភ័យខ្លាចរបបទឹកមិនទៀងទាត់ ហើយមានពេលខ្លះហូរគួចត្របាញ់យ៉ាងខ្លាំងក៏មាន ។ មូលហេតុចំបងទីពីរនោះគឺ បញ្ហាស្បៀងអាហារ ។ ការប្រែប្រួលរបស់ទឹកទន្លេសេសានបានធ្វើឱ្យធនធានទន្លេទាំងអស់ចុះអន់ថយយ៉ាងខ្លាំងក្នុងនោះត្រីដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ម្ហូបអាហារបានធ្លាក់ចុះគួរអោយព្រួយបារម្ភ ។ របបទឹកឡើងចុះមិនទៀង គុណភាពទឹកអន់ថយ ការបាត់បង់បន្លែព្រៃតាមដងទន្លេសេសាន និងការបាត់បង់មុខរបររែងមាសបានបង្កអោយអ្នកភូមិដែលរស់នៅពឹងអាស្រ័យលើធនធានទន្លេជួបប្រទះបញ្ហាខ្វះខាត់ស្បៀងអាហារ ។ ចំណែកឯមូលហេតុដ៏សំខាន់ទីបីគឺ សេចក្តីភ័យខ្លាច ទំនប់បាក់ដែលដិតដាមជាប់អារម្មណ៏របស់អ្នកភូមិដែលជាមូលហេតុនាំអោយផ្លាស់ទីលំនៅពីទន្លេ ។ មូលហេតុដ៏សំខាន់ ចុងក្រោយនោះ គឺដើម្បីការពារចំការរបស់ពួកគាត់

កុំអោយអ្នកខាងក្រៅភូមិចាប់យក និងដីទ័លគ្មានកន្លែងពង្រីកភូមិ ។

ការផ្លាស់ប្តូរទីលំនៅថ្មីនេះបានធ្វើអោយអ្នកភូមិទទួលរងនូវឥទ្ធិពលវិជ្ជមានផង និងអវិជ្ជមានផងដែរ ។ ចំពោះឥទ្ធិពលវិជ្ជមានដែលពួកគាត់កំពុងជួបប្រទះមានដូចជា សន្តិសុខស្បៀងអាចល្អប្រសើរជាងកន្លែងចាស់ ដោយសារនៅតំបន់ថ្មីសំបូរដីទំនេរ និងមានដីជាតិច្រើន អ្នកភូមិមិនឈឺញឹកញាប់ច្រើនដូចមុនដោយសារពួកគាត់មិនប្រើទឹកទន្លេ ហើយជាពិសេសពួកគេមិនភ័យខ្លាចទឹកទន្លេ និងទំនប់បាក់ទៀតឡើយ ពីព្រោះតំបន់ថ្មីនៅឆ្ងាយពីទន្លេ។ ចំណែកឯ ឥទ្ធិពលអវិជ្ជមានវិញមានដូចជា អ្នកភូមិជាច្រើននាក់បានបោះបង់ចោលដីស្រែចំការ និងដីភូមិនៅតាមដងទន្លេ មាន កុមារប្រមាណ ១,០០០ នាក់ មិនបានទទួលការអប់រំ ដោយសារតំបន់រស់នៅថ្មីស្ថិតនៅឆ្ងាយពីសាលារៀន ព្រៃឈើ ជាច្រើនហិចតាត្រូវបានអ្នកភូមិកាប់ធ្វើចំការនៅតំបន់ថ្មី នៅរដូវប្រាំងជួបប្រទះនឹងបញ្ហាខ្វះទឹកប្រើប្រាស់យ៉ាងខ្លាំង ហើយការធ្វើដំណើរជាការលំបាកយ៉ាងធ្ងន់ធ្ងរដែលធ្វើអោយការទំនាក់ទំនងមិនបានល្អ ។

នេះជាការព្រួយបារម្ភយ៉ាងធំធេងចំពោះជោគវាសនាជនរងគ្រោះដោយសារទំនប់វារីអគ្គិសនី ដែលរហូតមកដល់បច្ចុប្បន្ននេះយើងនៅតែមិនទាន់មានយន្តការ និងដំណោះស្រាយណាមួយត្រូវបានអនុវត្តឡើយ ។ តើទន្លេសេសាន និងសហគមន៍ដែលកំពុងរស់នៅតាមដងទន្លេនឹងស្ថិតនៅក្នុងស្ថានភាពបែបណា ប្រសិនបើបញ្ហាទាំងនេះនៅតែមាន និងរឹតតែធ្ងន់ធ្ងរឡើងៗ នោះ?

# សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះអាចបញ្ចប់ពេញលេញបានដោយសារតែមានការលះបង់ទាំងកំលាំងកាយចិត្ត និងពេលវេលាដ៏ គួរឱ្យកោតសរសើររបស់អ្នកសិក្សាស្រាវជ្រាវចំនួន ១៧ នាក់ នៅតាមដងទន្លេសេសាន និងមកពីទន្លេស្រែពក ។ ពួកគេ បានចូលរួមយ៉ាងពេញលេញដើម្បីសំរេចបានការសិក្សានេះ ។ ជាក់ស្តែងពួកគេជាអ្នកផ្តួចផ្តើម និងសំណូមពរឱ្យរៀបចំការសិក្សានេះឡើងតាំងពីដំបូង បន្ទាប់មកក៏បានរៀបចំផែនការចុះសិក្សា ចុះប្រមូលព័ត៌មានពីសហគមន៍មូលដ្ឋាន វិភាគព័ត៌មាន និងសរសេររបាយការណ៍សង្ខេបអំពីការរកឃើញរបស់ពួកគេ ។

យើងសូមសំដែងនូវការកោតសរសើរ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមដ៏ពេញលេញពីអ្នកស្រាវជ្រាវនៅតាមសហគមន៍មូលដ្ឋានទាំងអស់ដែលមានឈ្មោះដូចខាងក្រោម :

១-សៃ ប៊ុនឡាំ នៅភូមិតាឡាវ ឃុំតាឡាវ ស្រុកអណ្តូងមាស
២-ក្លាន លៀម នៅភូមិអូរកប ឃុំម៉ាលិក ស្រុក អណ្តូង មាស
៣-ផាន់ លេន នៅភូមិតាឡាវ ឃុំតាឡាវ ស្រុកអណ្តូងមាស
៤-ក្លាន ធី នៅភូមិវាលលែង ឃុំញ៉ាង ស្រុកអណ្តូងមាស
៥-រម៉ាម ម្លិ នៅភូមិផាដល ឃុំសេសាន ស្រុកអូរយ៉ាដាវ
៦-ពៅ ប៊ុនស៊ុំ នៅភូមិតាវែង ឃុំតាវែង ស្រុកតាវែង
៧-វែង ផាន្នី នៅភូមិ តាវែង ឃុំតាវែង ស្រុកតាវែង
៨-ភិត ភឿ នៅភូមិតាវែង ឃុំតាវែង ស្រុកតាវែង
៩-ញ៉ាង ប៊ុនចាន់ នៅភូមិតាវែង ឃុំតាវែង ស្រុកតាវែង
១០- ផាន់ ថងល្មៀន នៅភូមិទាមលើ ឃុំកាចូន ស្រុកវើនសៃ
១១- ងួន មុំ នៅភូមិប៉ង់ ឃុំប៉ង់ ស្រុកវើនសៃ
១២- ឡុត ស៊ុក នៅភូមិកាឡាន់ញ៉ៃ ឃុំវើនសៃ ស្រុកវើនសៃ
១៣- ហ៊ិង សឿន នៅភូមិហ្វាំង ឃុំបានប៉ុង ស្រុកវើនសៃ
១៤- ស៊ីន ថងឡាវ នៅភូមិលំផាត់ ឃុំជ័យឧត្តម ស្រុកលំផាត់
១៥- សៀន នូលៃ នៅភូមិថ្មី ឃុំជ័យឧត្តម ស្រុកលំផាត់
១៦- ធន់ ប៊ុនហាង នៅភូមិជីឡូ ឃុំជ័យឧត្តម ស្រុកលំផាត់
១៧- ណំ ផាន់នី នៅភូមិអូរកាន ឃុំជ័យឧត្តម ស្រុកលំផាត់

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គលិករបស់អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុងទាំងអស់ដែលបានចូលរួមក្នុងការសិក្សានេះ ជាពិសេសចំពោះលោក **ម៉ៅ សារឹម** ដែលបានចងក្រង និងសរសេររបាយការណ៍នេះ ។ ជាមួយគ្នា នេះក៏សូមថ្លែងអំណរគុណចំពោះកញ្ញា **អេមមី ត្រេនដឹម** ដែលបានជួយរៀបចំ សិក្ខាសាលាបណ្តុះបណ្តាលពីវិធីសាស្ត្រនៃការស្រាវជ្រាវ និងបានផ្តល់យោបល់កែលំអសំរាប់ការសិក្សានេះ ។ សូម អរគុណយ៉ាងខ្លាំងចំពោះ លោកស្រី **ណាង ណយ** និង លោក **ម៉ៀច មាន** ដែលបានជួយសំរបសំរួលដល់ការចុះប្រមូលព័ត៌មាននៅតាមសហគមន៍មូលដ្ឋាន និងផ្តល់យោបល់ទាក់ទងទៅនឹងខ្លឹមសារនៃរបាយការណ៍សិក្សានេះ ។ សូមអរគុណយ៉ាងពិសេសចំពោះលោក **គីម សង្ហា** ដែលបានផ្តល់ប្រឹក្សាបច្ចេកទេសសំរាប់ការសិក្សា និងជួយផ្តល់យោបល់កែលំអរបាយការណ៍សិក្សានេះ ។

សូមថ្លែងអំណរគុណដល់ក្រុមប្រឹក្សាឃុំ មេភូមិ និងប្រជាជនតាមភូមិ និងឃុំដែលបានចុះទៅសិក្សានៅសហគមន៍មូលដ្ឋាន តាមដងទន្លេសេសាន និងអ្នកផ្សេងៗទៀត ដែលបានចូលរួមចំណែកផ្តល់ព័ត៌មានសំរាប់ការសិក្សានេះ ។

# ១ ~ សេចក្តីផ្តើម

ទន្លេសេសានមានប្រភពដើមនៅតំបន់ខ្ពង់រាបកណ្តាលក្នុងខេត្តយ៉ាឡាយ និងកន្ទូមនៃប្រទេសវៀតណាម ហើយវាជាដៃដ៏សំខាន់របស់ទន្លេមេគង្គ ។ ទន្លេនេះហូរកាត់ខេត្តចំនួន ២ នៅក្នុងប្រទេសកម្ពុជា គឺខេត្តរតនគីរី និងខេត្តស្ទឹងត្រែង រួចហូរប្រសព្វគ្នាជាមួយទន្លេស្រែពក និងសេកុងចូលទៅក្នុងទន្លេមេគង្គនៅទីរួមខេត្តស្ទឹងត្រែង ។ នៅក្នុង ខេត្តរតនគីរី ទន្លេសេសានហូរកាត់ស្រុកចំនួន ៤ រួមមាន ស្រុកអូរយ៉ាដាវ ស្រុកអណ្តូងមាស ស្រុកតាវែង និងស្រុកវ៉ឺនសៃ ។ ទន្លេនេះផ្តល់ជំរក និងមធ្យោបាយចិញ្ចឹមជីវិតដល់សត្វ និងមនុស្សរាប់ម៉ឺននាក់ដែលពឹងអាស្រ័យលើវាតាំងពីយូរយារណាស់មកហើយ ។ បច្ចុប្បន្នមានប្រជាជនប្រមាណ ៤៧៩៣ គ្រួសារ កំពុងរស់នៅ និងពឹងអាស្រ័យលើវា ។ អ្នកភូមិទាំងនោះរស់នៅចំរុះជាតិសាសន៍ ប្រពៃណី និងវប្បធម៌ ដែលក្នុងនោះជនជាតិដើមភាគតិចមានចំនួនច្រើនជាងគេ ។ ជនជាតិដើមភាគតិចទាំងនោះរួមមានជនជាតិចារាយ ព្រៅ គ្រឹង កាវែត លុន ទំពួន កាចក និងភ្នង ។ អ្នកភូមិ រស់នៅតាមដងទន្លេសេសានដោយប្រកបរបរចិញ្ចឹមជីវិតតាមលក្ខណៈប្រពៃណីដូចជាការធ្វើចំការ និងធ្វើស្រែ និងមានមុខរបរបន្ទាប់បន្សំផ្សេងៗ ទៀតដូចជា ដាំដំណាំរួមផ្សំ ចិញ្ចឹមសត្វមាន់ ជ្រូក គោ និងក្របី នេសាទ និងពឹងផ្អែកលើធនធានធម្មជាតិ ។ល ។

ទំនប់វារីអគ្គីសនីយ៉ាលីដែលមានកំលាំង ៧២០ មេហ្គាវ៉ាត់ ត្រូវបានចាប់ផ្តើមសាងសង់នៅឆ្នាំ ១៩៩៣ នៅលើដងទន្លេសេសានក្នុងប្រទេសវៀតណាម ដែលមានចំងាយប្រមាណ ៧៥ គីឡូម៉ែត្រ ពីព្រំប្រទល់កម្ពុជា-វៀតណាម ។ ទំនប់នេះចាប់ផ្តើមប្រតិបត្តិការពេញលេញនៅឆ្នាំ ២០០១ ។ នៅក្នុងកំឡុងពេលកំពុងសាងសង់ (ឆ្នាំ១៩៩៦) និងក្រោយពេលទំនប់នេះធ្វើប្រតិបត្តិការពេញលេញរួចមក ធនធានធម្មជាតិ សត្វ និងអ្នកភូមិដែលរស់នៅតាមដងទន្លេសេសាន បានទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំង និងឈឺចាប់យ៉ាងខ្លោចផ្សា ។ អ្នកភូមិដែលរស់នៅតាមដងទន្លេមានប្រព័ន្ធចិញ្ចឹមជីវិតដោយមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងរបបទឹកទន្លេសេសាន និងធនធានផ្សេងៗ ទៀតរបស់ទន្លេនេះ ហើយនៅពេលទន្លេបាត់បង់នូវលក្ខណៈធម្មជាតិរបស់ខ្លួនដោយសារទទួលរងនូវឥទ្ធិពលអវិជ្ជមានពីទំនប់នោះ វាធ្វើអោយការចិញ្ចឹមជីវិតរបស់អ្នកភូមិជួបប្រទះនឹងបញ្ហាជាច្រើន ។ របបទឹកទន្លេប្រែប្រួលខុសប្រក្រតី ទឹកជំនន់ កើតមានឡើងញឹកញាប់ទាំងរដូវវស្សា និងរដូវប្រាំង ការបាត់បង់បន្លែព្រៃតាមដងទន្លេ អ្នកភូមិមិនអាចដាំបន្លែក្នុង សួនតាមច្រាំងទន្លេបានដូចមុន គុណភាពទឹកធ្លាក់ចុះ ផលត្រីធ្លាក់ចុះគួរអោយព្រួយបារម្ភ និងអ្នកភូមិបាត់បង់ជីវិតដោយសារទឹកទន្លេគួច ទាំងអស់នេះគឺសុទ្ធតែជាផលប៉ះពាល់អវិជ្ជមានចំបងៗ ដែលទំនប់យ៉ាលីបានផ្តល់អោយចាប់តាំងពីឆ្នាំ ១៩៩៦ មក ។

នៅឆ្នាំ ១៩៩៦ អ្នកភូមិតាមដងទន្លេសេសានបានទទួលរងនូវមហាគ្រោះទឹកជំនន់យ៉ាងខ្លាំងដែលបង្កឡើង ដោយទឹកធ្លាយចេញពីទំនប់យ៉ាលី ។ នៅពេលនោះភូមិដ្ឋានប្រជាជន ទ្រព្យសម្បត្តិផ្សេងៗ ស្រូវក្នុងស្រែ និងស្រូវក្នុង ជង្រុកសត្វ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈត្រូវបានជន់លិចនិងខូចខាតយ៉ាងធ្ងន់ធ្ងរ ។ មិនតែប៉ុណ្ណោះនៅឆ្នាំបន្តបន្ទាប់ ក្រោយៗមកទៀតអ្នកភូមិបានទទួលរងគ្រោះទឹកជំនន់យ៉ាងញឹកញាប់ រហូតដល់ឆ្នាំខ្លះទឹកជំនន់អាចមានដល់ ៣ ទៅ ៤ ដងឯណោះ ។ នៅកំឡុងពេលកំពុងសាងសង់ទំនប់ពី ឆ្នាំ ១៩៩៦ ដល់ ឆ្នាំ ២០០០ មានអ្នកភូមិចំនួន ៣២ នាក់ ត្រូវបាន ស្លាប់ដោយសារលង់ទឹកដែលបណ្តាលមកពីការបើកទឹកខ្លាំងពីទំនប់ ។

ដោយការគិតគូរ និងយកចិត្តទុកដាក់ខ្លាំងចំពោះផលប៉ះពាល់របស់ទំនប់មកលើសង្គមអ្នកភូមិនៅតាមដងទន្លេសេសានបានធ្វើការសិក្សាស្រាវជ្រាវមួយនេះឡើងដោយមានការជួយជ្រោមជ្រែងផ្នែកបច្ចេកទេសពី **អង្គការបណ្តាញ ការពារទន្លេសេសាន ស្រែពក សេកុង** ។ របាយការណ៍សិក្សានេះនឹងបង្ហាញជូននូវទិដ្ឋភាពលំអិតជុំវិញការចាកចេញពី ទន្លេសេសានរបស់អ្នកភូមិដែលធ្លាប់រស់នៅពឹងអាស្រ័យលើទន្លេនេះជាយូរយារមកហើយ ។ ទិដ្ឋភាពចំបងៗរួមមាន : ស្ថានភាពទូទៅនៃការចាកចេញពីទន្លេ មូលហេតុនៃការចាកចេញ និងឥទ្ធិពលនៃការចាកចេញពីទន្លេ ។

## ២ ~ គោលដៅ និងគោលបំណងនៃការសិក្សា

**២.១ គោលដៅនៃការសិក្សា** : ស្វែងរកអោយឃើញនូវមូលហេតុនៃការផ្លាស់ទីលំនៅ និងលើកកំពស់ការយល់ដឹងដល់សហគមន៍ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀតអំពីផលប៉ះពាល់លើផ្នែកសេដ្ឋកិច្ចសង្គម និងបរិស្ថាន សិទ្ធិមនុស្សដែលបង្កឡើងដោយទំនប់នៅលើដងទន្លេសេសាន និងដើម្បីជាវិភាគទានដល់ការចូលរួមស្វែងរកដំណោះស្រាយសមស្របនៅពេលអនាគត ។

**២.២ គោលបំណងនៃការសិក្សា** : ការសិក្សាស្រាវជ្រាវដោយសហគមន៍នេះមានគោលបំណងជាក់លាក់ដូចខាងក្រោមនេះ :

- ស្វែងរកឱ្យឃើញពីបរិមាណប្រជាជនដែលកំពុងរស់នៅ និងបានចាកចេញពីទន្លេសេសានក្នុងខេត្ត រតនគិរី ដោយមានការពាក់ពន្ធ័ទៅ និងការផ្លាស់ប្តូររបស់ទន្លេសេសាន ។
- ស្វែងរកអោយឃើញនូវមូលហេតុចំបង និងឥទ្ធិពលនៃចាកចេញពីទន្លេរបស់ប្រជាជនដែលធ្លាប់ពឹង អាស្រ័យលើទន្លេសេសានតាំងពីយូរមកហើយ ។
- កសាងសមត្ថភាពអ្នកភូមិលើការសិក្សាស្រាវជ្រាវដោយមានការចូលរួម និងអនុវត្តដោយសហគមន៍ ខ្លួនឯង ។

## ៣ ~ តំបន់សិក្សា និងព្រំដែននៃការសិក្សា

ឆ្លើយតបទៅនឹងគោលបំណងសិក្សាខាងលើការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងនៅក្នុងស្រុកទាំង ៤ នៅតាមដងទន្លេសេសានក្នុងខេត្តរតនគិរី ។ ដើម្បីកំណត់និងរកអោយឃើញនូវលទ្ធផលសិក្សាជាវិជ្ជមានសំរាប់តំបន់អាង ទន្លេសេសាននៅក្នុងខេត្តរតនគិរីអំពីការរុះរើទីលំនៅដ្ឋាន និងការចាកចេញពីទន្លេសេសានរបស់អ្នកភូមិការសិក្សានេះ ត្រូវបានសិក្សាតំណាងអោយអ្នកស្រុកតាមដងទន្លេសេសានទាំងអស់នៅក្នុងខេត្ត ។ ស្រុកទាំង ៤ ដែលក្រុមសិក្សាស្រាវជ្រាវយើងបានចុះទៅសិក្សារួមមាន :

១- ស្រុកអូរយ៉ាដាវ

២- ស្រុកអណ្តូងមាស

៣- ស្រុកតាវែង និង ៤- ស្រុកវ៉ឺនសៃ

## តារាងទី ១ : អ្នកសិក្សាស្រាវជ្រាវ

| ល.រ | នាម គោត្តនាម | ភេទ | ជនជាតិ | តួនាទី | អាសយដ្ឋាន | | |
|---|---|---|---|---|---|---|---|
| | | | | | ភូមិ | ឃុំ | ស្រុក |
| ១ | រម៉ាម ម្លិ | ប | ចារាយ | ជនបង្គោលភូមិ | ផាដល | សេសាន | អូរយ៉ាដាវ |
| ២ | សៃ ប៊ុនឡាំ | ប | ឡាវ | ជនបង្គោលស្រុក | តាឡាវ | តាឡាវ | អណ្តូងមាស |
| ៣ | ក្លាន លៀម | ស | ចារាយ | ជនបង្គោលស្រុក | អូរកប | ម៉ាលិក | អណ្តូងមាស |
| ៤ | ផាន់ លេន | ស | ឡាវ | ចាស់ទុំស្រុក | តាឡាវ | តាឡាវ | អណ្តូងមាស |
| ៥ | ក្លាន ធី | ប | ចារាយ | ចាស់ទុំស្រុក | វាលលែង | ញ៉ាង | អណ្តូងមាស |
| ៦ | ពៅ ប៊ុនស៊ុំ | ប | ព្រៅ | ជនបង្គោលស្រុក | តាវែង | តាវែង | តាវែង |
| ៧ | វែង ផាន់នី | ស | ព្រៅ | ជនបង្គោលស្រុក | តាវែង | តាវែង | តាវែង |
| ៨ | ភិត ភឿ | ប | ព្រៅ | ចាស់ទុំស្រុក | តាវែង | តាវែង | តាវែង |
| ៩ | ញ៉ង ប៊ុនចាន់ | ប | ព្រៅ | ចាស់ទុំស្រុក | តាវែង | តាវែង | តាវែង |
| ១០ | ផាន់ ថងលៀន | ប | ទំពួន | ជនបង្គោលស្រុក | ទាមលើ | កាចូន | វើនសៃ |
| ១១ | ងួន មុំ | ស | ឡាវ | ជនបង្គោលស្រុក | ប៉ង់ | ប៉ង់ | វើនសៃ |
| ១២ | ឡុត ស៊ុក | ប | ឡាវ | ចាស់ទុំស្រុក | កាឡាន់ញ៉ែ | វើនសៃ | វើនសៃ |
| ១៣ | ហ៊ីង សឿន | ប | ឡាវ | ចាស់ទុំស្រុក | ហ្វាំង | បានប៉ុង | វើនសៃ |
| ១៤ | ណំ ផាន់នី | ស | ខ្មែរ | ចាស់ទុំស្រុក | អូរកាន | ជ័យឧត្តម | លំផាត់ |
| ១៥ | សៀន នូឡៃ | ប | ឡាវ | ចាស់ទុំស្រុក | ថ្មី | ជ័យឧត្តម | លំផាត់ |
| ១៦ | ស៊ីន ថងឡាវ | ស | ឡាវ | ជនបង្គោលស្រុក | លំផាត់ | ជ័យឧត្តម | លំផាត់ |
| ១៧ | ធន់ ប៊ុនហាង | ប | ខ្មែរ | ជនបង្គោលស្រុក | ដីឡូ | ជ័យឧត្តម | លំផាត់ |

ឃុំសេសានក្នុងស្រុកអូរយ៉ាដាវ គឺជាឃុំដែលស្ថិតនៅផ្នែកខ្សែទឹកខាងលើគេ ហើយដែលផ្នែកខាងលើរបស់ស្រុកមានព្រំប្រទល់ជាប់ប្រទេសវៀតណាម និងផ្នែកខាងក្រោមជាប់ស្រុកអណ្តូងមាស ។ នៅក្នុងឃុំនេះមានភូមិចំនួន ៣ នៅតាមដងទន្លេសេសាន ហើយក្នុងនោះក្រុមសិក្សាបានចុះទៅសិក្សាផ្ទាល់ក្នុងភូមិចំនួន ២ គឺភូមិប៉ាដល និងភូមិភិ ចំណែកឯភូមិមួយទៀតដែលមិនបានចុះទៅដល់គឺភូមិកាតាំង ។

ស្រុកអណ្តូងមាសស្ថិតនៅជាប់ស្រុកអូរយ៉ាដាវ និងជាប់ស្រុកតាវែងនៅផ្នែក ខ្សែទឹកខាងក្រោម ។ ក្រុមសិក្សា បានចុះទៅសិក្សាផ្ទាល់បានចំនួន ២ ឃុំ ក្នុងនោះមាន ១០ ភូមិ ដោយរួមទាំងភូមិបែកថ្មីផងដែរ ហើយលទ្ធផលដែលទទួលបានពីភូមិទាំង ១០ នោះនឹងប្រើប្រាស់សំរាប់ផ្ទះបញ្ជាំងអោយភូមិទាំង ១២ នៅក្នុងស្រុកអណ្តូងមាសទាំងមូលដែលសុទ្ធតែជាភូមិមានប្រជាជនបោះបង់ទីលំនៅ ។

ភូមិទាំងនោះមាននៅក្នុងតារាងខាងក្រោម ៖

**តារាងទី ២ ៖ ភូមិដែលបានសិក្សា**

| ល.រ | ភូមិ | ឃុំ | ស្រុក |
|---|---|---|---|
| ០១ | ញ៉ាង | ញ៉ាង | អណ្តូងមាស |
| ០២ | តាំងមួ | ញ៉ាង | អណ្តូងមាស |
| ០៣ | តាំងលោម | ញ៉ាង | អណ្តូងមាស |
| ០៤ | តាំងជិក | ញ៉ាង | អណ្តូងមាស |
| ០៥ | ដាលប៉ក់ | ញ៉ាង | អណ្តូងមាស |
| ០៦ | ដាលញ៉ូវ | ញ៉ាង | អណ្តូងមាស |
| ០៧ | ណាយ | ញ៉ាង | អណ្តូងមាស |
| ០៨ | កាជូតភ្នំ | ញ៉ាង | អណ្តូងមាស |
| ០៩ | តាណង | តាឡាវ | អណ្តូងមាស |
| ១០ | កាណាតធំ | តាឡាវ | អណ្តូងមាស |

ចំណែកឯស្រុកតាវែងវិញស្ថិតនៅចន្លោះស្រុកអណ្តូងមាស និងស្រុកវ៉ឺនសៃ ។ ក្រុមសិក្សាបានចុះទៅដល់ភូមិ ចំនួន ៥ តាមការគ្រោងទុក ប៉ុន្តែមានភូមិចំនួន ១ ទេ ដែលត្រូវបានជ្រើសរើសយកមកសិក្សា ព្រោះភូមិនោះបានបោះបង់ និងផ្លាស់ប្តូរទីលំនៅ ។ ភូមិនោះមានឈ្មោះថា ភូមិកិត្តួងក្រោម ដែលស្ថិតនៅក្នុងឃុំតាវែងក្រោម ។

ស្រុកវ៉ឺនសៃជាស្រុកដែលនៅផ្នែកខ្សែទឹកខាងក្រោមគេក្នុងចំណោមស្រុកទាំង ៤ ហើយវានៅជាប់ព្រំប្រទល់ ខេត្តស្ទឹងត្រែង ។ ស្រុកវ៉ឺនសៃមានភូមិចំនួន ២៦ ឃុំចំនួន ៩ ដែលស្ថិតនៅតាមដងទន្លេសេសាន ហើយក្នុងចំណោមភូមិ ទាំងនោះមានតែភូមិចំនួន ៥ ទេ ដែលមានប្រជាជនបោះបង់ និងផ្លាស់ប្តូរទីលំនៅ ។ ភូមិទាំង ៥ នោះមានដូចខាង ក្រោម ៖

១- ភូមិប៉ាតឹង ឃុំកោះប៉ង់

២- ភូមិឃួន ឃុំកោះពាក

៣- ភូមិ ផាកណាម ឃុំកោះពាក

៤- ភូមិកាចូនក្រោម ឃុំកាចូន

៥- ភូមិបានប៉ុង ឃុំបានប៉ុង

ដូចនេះការស្រាវជ្រាវនេះបានសិក្សាលំអិតលើភូមិចំនួន ១៩ ដែលជាភូមិមានបញ្ហាពាក់ព័ន្ធនឹងការបោះបង់ និងផ្លាស់ប្តូរទីលំនៅរបស់អ្នកភូមិដែលធ្លាប់រស់នៅតាមដងទន្លេតាំងពីយូរណាស់មកហើយ ។ ចំនួនភូមិដែលបានជ្រើសរើសយកមកសិក្សាច្រើនជាងគេ គឺនៅស្រុកអណ្តូងមាស ។

## ៤ ~ វិធីសាស្ត្រសិក្សា

ការសិក្សាអំពីការចាកចេញពីទន្លេសេសានរបស់អ្នកភូមិក្នុងខេត្តរតនគិរី គឺត្រូវបានធ្វើឡើងដោយអ្នកភូមិដែលរស់នៅតាមដងទន្លេសេសាន និងអ្នកភូមិមកពីទន្លេស្រែពក ។ អ្នកភូមិដែលរស់នៅតាមដងទន្លេសេសាន និងអ្នកភូមិមួយចំនួនទៀតមកពីទន្លេស្រែពកបានដើរតួនាទីជាអ្នកសិក្សាស្រាវជ្រាវនេះ ហើយអង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង គ្រាន់តែដើរតួជាអ្នកសំរបសំរួល និងជួយជ្រោមជ្រែងផ្នែកបច្ចេកទេសប៉ុណ្ណោះ ។ អ្នកភូមិចំនួន ១៦ នាក់ ( ស្ត្រី ៨ នាក់) ក្នុងនោះមាន ៤ នាក់ មកពីទន្លេស្រែពក គឺជាអ្នកសិក្សាស្រាវជ្រាវលើបញ្ហាចាកចេញពីទន្លេសេសានរបស់អ្នកភូមិ ដែលជាប្រធានបទនៃការសិក្សានេះ ។

ស្របតាមខ្លឹមសារនៃការសិក្សាស្រាវជ្រាវដោយសហគមន៍ខាងលើ ការសិក្សានេះត្រូវបានផ្តួចផ្តើមឡើង ដោយអ្នកភូមិ ហើយក្រោយមកមានការពិភាក្សាអំពីការបង្កើតក្រុមសិក្សាមួយក្រុមសំរាប់ធ្វើការសិក្សាស្រាវជ្រាវនេះ នៅដើមខែ ឧសភា ឆ្នាំ ២០០៦ ។ ក្រោយមកអង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលក្រុមសិក្សានោះនៅថ្ងៃទី ២១-២៤ ខែ ឧសភា ឆ្នាំ ២០០៦ ហើយនៅចុងបញ្ចប់នៃសិក្ខាសាលានេះក្រុមសិក្សាបានប្រជុំពិភាក្សាបង្កើតផែនការសិក្សាលំអិតមួយ ។ អនុលោមតាមផែនការអ្នកស្រាវជ្រាវទាំង ១៦ នាក់ ត្រូវបានបែងចែកជា ៤ក្រុម ផ្សេងៗគ្នា ដោយក្រុមមួយត្រូវចុះទៅសិក្សានៅក្នុងស្រុកចំនួនមួយ ។ ការចុះសិក្សាតាមសហគមន៍ក្នុងស្រុកទាំង ៤ ត្រូវបានធ្វើឡើងចាប់ពីចុងខែ ឧសភា ដល់ដើមខែ កក្កដា ឆ្នាំ ២០០៦ ។

នៅចុងបញ្ចប់នៃការចុះសិក្សាតាមមូលដ្ឋាន ក្រុមសិក្សានិមួយៗ បានជួបជុំគ្នាដើម្បីបង្ហាញ និងផ្ទៀងផ្ទាត់លទ្ធផលសិក្សាដែលរកឃើញភ្លាមៗ ។ ដើម្បីប្រមូលព័ត៌មានបន្ថែម និងផ្ទៀងផ្ទាត់លទ្ធផលសិក្សាថ្មីពីស្រុកនិមួយៗ ក្រុមសិក្សាស្រាវជ្រាវបានរៀបចំសិក្ខាសាលាបង្ហាញ និងផ្ទៀងផ្ទាត់លទ្ធផលសិក្សាថ្នាក់ស្រុកចំនួន ៣ ដង នៅក្នុងខែ កក្កដា ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ ដូចជាអភិបាលស្រុក ក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងអ្នកភូមិដែលបានសម្ភាស ។ ហើយនៅដើមខែ តុលា ក្រុមសិក្សាបានរៀបចំសិក្ខាសាលាថ្នាក់ខេត្តចំនួន ២ លើក ដើម្បីផ្ទៀងផ្ទាត់លទ្ធផលសិក្សាចុងក្រោយ ។

ការសិក្សានេះមាន ៣ ផ្នែកសំខាន់ៗ គឺ :

- ផ្នែកទី ១ គឺបណ្តុំព័ត៌មានទូទៅស្តីពីលក្ខណៈនៃការចាកចេញពីទន្លេសេសាន អ្នកចាកចេញពីទន្លេ ទីកន្លែងថ្មីដែលអ្នកភូមិកំពុង
- រស់នៅ ព័ត៌មានបរិមាណស្តីពីចំនួនអ្នកភូមិដែលបានចាកចេញពីទន្លេសេសាន និង ប្រជាជនដែលកំពុងរស់នៅតាមដងទន្លេ ។
- ផ្នែកទី ២ គឺបង្ហាញអំពីមូលហេតុចំបងៗ នៃការចាញចេញពីទន្លេសេសានរបស់អ្នកភូមិដែលធ្លាប់រស់ នៅតាមដងទន្លេនេះតាំងពីយូរណាស់មកហើយ ។
- ផ្នែកទី ៣ គឺជាលទ្ធផលនៃការអង្កេត លើឥទ្ធិពលនៃការចាកចេញពីទន្លេសេសាន ក្នុងនោះយើងលើកឡើងទាំងគុណសម្បត្តិ និងគុណវិបត្តិដែលមានការពាក់ព័ន្ធទៅនឹងមធ្យោបាយចិញ្ចឹមជីវិតរបស់អ្នក ភូមិទាំងនោះ ។

ដើម្បីសំរេចបានលទ្ធផលសិក្សាតាមការគ្រោងទុកសំខាន់ៗ ទាំង ៣ ផ្នែកខាងលើ ក្រុមសិក្សាស្រាវជ្រាវបាន ប្រើប្រាស់នូវវិធីសាស្ត្រ និងបច្ចេកទេសចំបងៗមួយចំនួនដូចខាងក្រោម :

**៤.១ សិក្សាអំពីឯកសារផ្សេងៗ :** នៅផ្នែកនេះក្រុមសិក្សាបាន សិក្សាស្វែងយល់បន្ថែមលើឯកសារពាក់ព័ន្ធមួយចំនួន ដែលមានស្រាប់ ដូចជាស្ថិតិភូមិ ឃុំ ការសិក្សាអំពីបញ្ហាទន្លេសេសាន និងការសិក្សាផ្សេងៗទៀត ដែលពាក់ព័ន្ធ ។

**៤.២ ការសំភាសន៍សមាគមន៍ :** ក្រុមសិក្សាបានរៀបចំបញ្ជីសំណួរច្បាស់លាស់សំរាប់សម្ភាសន៍ប្រភពផ្តល់ព័ត៌មានសំខាន់ ៣ គឺក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងអ្នកភូមិដែលចាកចេញពីទន្លេសេសាន ។ បញ្ជីសំណួរទាំង ៣ ប្រភេទខុសៗគ្នា នោះត្រូវបានប្រើសំរាប់អ្នកភូមិ ។ ម្យ៉ាងទៀត បើទោះបីជាមានបញ្ជីសំណួរទាំង នេះក្តីការសំភាសន៍ត្រូវបានធ្វើឡើងជាលក្ខណៈពាក់កណ្តាលផ្លូវការ ដោយអ្នកសំភាសន៍អាចសាកសួរសំណួរពាក់ព័ន្ធបន្ថែមលើសំណួរដែលបានរៀបចំ ។

**៤.៣ ការពិភាក្សាជាក្រុម :** ក្រៅពីនោះក្រុមសិក្សាបានរៀបចំការពិភាក្សាជាក្រុមតាមភូមិដែលបានចុះទៅសិក្សាទៀតផង ។ ការពិភាក្សាជាក្រុមមានការចូលរួមពីបុរស ស្ត្រី និងយុវជន ដើម្បីកំណត់អាទិភាព មូលហេតុនៃការចាកចេញពីទន្លេរបស់អ្នកភូមិ និងចាត់ចំណាត់ថ្នាក់បញ្ហាដែលអ្នកភូមិជួបប្រទះនៅកន្លែងថ្មី ។ ប៉ុន្តែមានភូមិខ្លះ ក្រុមសិក្សាមិនអាចធ្វើការពិភាក្សាជាក្រុមបានទេដោយសារខ្វះពេលវេលា និងការចូលរួមពីអ្នកភូមិ ។

**៤.៤ ការអង្កេតទូទៅ :** ក្រុមសិក្សាបានធ្វើការអង្កេតយ៉ាងយកចិត្តទុកដាក់អំពីស្ថានភាពទូទៅនៃភូមិដែល ត្រូវបានអ្នកភូមិបោះបង់ និងផ្លាស់ប្តូរស្ថានភាពរស់នៅរបស់អ្នកភូមិនៅក្នុងតំបន់ថ្មីទាំងនោះ ។ ការអង្កេតនេះជាឧបករណ៍ ដ៏សំខាន់សំរាប់ក្រុមសិក្សាក្នុងការវិភាគពីផលប៉ះពាល់នៃការចាកចេញពីទន្លេ សេសានរបស់អ្នកភូមិ ។

## ៥ ~ លទ្ធផលសិក្សា

### ៥.១ ទិដ្ឋភាពទូទៅនៃការចាញចេញពីទន្លេ ចំនួនប្រជាជនចាកចេញពីទន្លេ និងកំពុងរស់នៅតាមដងទន្លេ

ជាទូទៅការបោះបង់ និងផ្លាស់ប្តូរទីលំនៅរបស់អ្នកភូមិមានពីរប្រភេទខុសគ្នា គឺការចាកចេញជាក្រុម និងការចាកចេញជាភូមិទាំងមូលតែម្តង ។ លក្ខណៈនៃការចាកចេញរបស់អ្នកភូមិនៅតាមស្រុកទាំង៤ រួមមានស្រុកអូរយ៉ាដាវ ស្រុកអណ្តូងមាស ស្រុកតាវែង និងស្រុកវើនសៃ គឺស្ថិតនៅក្នុងលក្ខណៈទាំងពីរខាងលើ ប៉ុន្តែមានភូមិខ្លះ នៅមានប្រជា ជនបានចាកចេញពីទន្លេជាក្រុម ហើយភូមិមួយចំនួនទៀតបានបោះបង់ និងផ្លាស់ប្តូរទីលំនៅពីភូមិទាំងអស់គ្នាតែម្តង ។ ស្រុក ១ ក្នុង ចំណោមស្រុកទាំង ៤ មានប្រជាជានបោះបង់ និងផ្លាស់ប្តូរទីលំនៅពីទន្លេដោយរើភូមិតែម្តង ។

**-ស្រុកអូរយ៉ាដាវ :** អ្នកភូមិបានបោះបង់ទីលំនៅចេញពីទន្លេសេសានជាក្រុមតែប៉ុណ្ណោះ ។ អ្នកដែលបោះបង់ ទីលំនៅទាំងនោះជាជនជាតិដើមភាគតិចចារាយ ដែលជាប្រជាជនរស់នៅភូមិភិ ។ ភូមិភិជាភូមិមួយក្នុងចំណោមភូមិ ទាំង ៣ ក្នុងឃុំសេសានដែលស្ថិតនៅតាមដងទន្លេសេសាន ។ ភូមិទាំងនេះរួមមាន ភូមភិ, ភូមិកាតាំង និងភូមិប៉ាដល ហើយភូមិភិ ជាភូមិដែលស្ថិតនៅផ្នែកខ្សែទឹកខាងលើគេបំផុត ។ ប្រជាជននៅភូមិទាំងនេះ ប្រកបមុខរបរធ្វើស្រែ ចំការ និងដាំដំណាំផ្សេងៗនៅតាមដងទន្លេ ។

ក្រុមសិក្សាបានរកឃើញថាមានប្រជាជនចំនួន ៤ គ្រួសារ ដែលមានសមាជិកចំនួន ១៥ នាក់ ក្នុងនោះមានស្រី ចំនួន ៨នាក់ ជាជនជាតិដើមភាគតិចចារាយទាំងអស់បានបោះបង់ និងផ្លាស់ប្តូរទីលំនៅពីភូមិមាត់ទន្លេទៅរស់នៅតំបន់ភ្នំឆ្ងាយពីភូមិចាស់តាំងពីឆ្នាំ២០០៣ ។ តំបន់ថ្មីដែលគេរស់នៅមានឈ្មោះហៅថា អូរត្រាវ និងអូរផ្លា ។ តំបន់ថ្មីទាំងនេះ ស្ថិតនៅភាគឦសាន្តនៃស្រុកអូរយ៉ាដាវ ដែលមានចំងាយប្រមាណ ៣០ គីឡូម៉ែត្រ ពីភូមិចាស់ ។ អូរត្រាវ និងអូរផ្លា គឺជាតំបន់ព្រៃភ្នំ ដែលស្ថិតនៅប្រមាណជា ១៥គីឡូម៉ែត្រ ពីព្រំដែនកម្ពុជា និងវៀតណាម ។ អ្នកភូមិទាំងនោះរស់នៅ ដោយពឹងអាស្រ័យលើធនធានធម្មជាតិនៅតំបន់ព្រៃភ្នំទាំងស្រុងសំរាប់ការផ្គត់ផ្គង់ម្ហូបអាហាររបស់ពួកគេ ។ អ្នកភូមិប្រកបរបរចិញ្ចឹមជីវិតដោយ ការធ្វើចំការព្រៃដុតដែលដាំស្រូវចំរុះជាមួយបន្លែរមផ្សំផ្សេងៗទៀត និងចិញ្ចឹមសត្វមួយចំនួន ដូចជា មាន់ ទា ជ្រូក គោ និងក្របីជាដើម ។ នៅបច្ចុប្បន្ននេះភូមិទាំង៣ ខាងលើមានប្រជាជនចំនួន២៣២គ្រួសារ ដែលមានសមាជិកសរុបចំនួន ១,០៧២ នាក់ ដែលក្នុងនោះមានស្ត្រីចំនួន ៥៤៣ នាក់ ។

**-ស្រុកអណ្តូងមាស :**មានប្រជាជនចំនួន ១២ ភូមិ ដែលរស់នៅតាមដងទន្លេសេសានក្នុងនោះមានជនជាតិ ដើមភាគតិចចារាយ កាចក់ ទំពួន ឡាវ ហើយក៏មានខ្មែររស់នៅទីនោះផងដែរ ដែលក្នុងនោះមានជនជាតិដើមភាគតិច ចារាយ ជាប្រជាជនច្រើនជាងគេ ។ អ្នកភូមិទាំងនោះប្រកបរបរចិញ្ចឹមជីវិតដោយការធ្វើស្រែចំការនិងដាំដំណាំរួមផ្សំ នៅតាមដងទន្លេ និងនៅតាមតំបន់ភ្នំឆ្ងាយពីទន្លេសេសានបន្តិច ។ ទន្ទឹមនឹងការធ្វើស្រែចំការ អ្នកភូមិទាំងនោះក៏ចិញ្ចឹមសត្វមួយចំនួន ដូចជា មាន់ ទា ជ្រូក គោ និងក្របី ។ ជាទូទៅអ្នកភូមិដែលរស់នៅតាមដងទន្លេធ្វើស្រែផង និងធ្វើចំការផង ដោយសារនៅតាមដងទន្លេដីនៅតំបន់ខ្លះជាដីទំនាប និងដីតំបន់ខ្លះជាតំបន់ខ្ពង់រាប ។ ប៉ុន្តែជាទូទៅប្រជាជនដែលរស់នៅតំបន់ភ្នំធ្វើតែចំការ ដាំស្រូវ បន្លែ និងដំណាំរួមផ្សំមួយចំនួនប៉ុណ្ណោះ ។

ការបោះបង់ និងការផ្លាស់ប្តូរទីលំនៅពីភូមិចាស់នៅតាមដងទន្លេក្នុងស្រុកអណ្តូងមាសមានទាំងរូបភាពចាក ចេញជាក្រុម និងចាកចេញដោយរើភូមិទាំងមូលតែម្តង ។ នៅភូមិមួយចំនួន ការបោះបង់និងការផ្លាស់ប្តូរទីលំនៅជាក្រុមរបស់អ្នកភូមិពីភូមិចាស់មួយអាចបង្កើតបានជាភូមិថ្មីតូចៗពីរទៅបីភូមិឯណ្ណោះ នេះក៏ដោយសារតែតំបន់ថ្មីដែល អ្នកភូមិផ្លាស់ទៅរស់នៅនោះស្ថិតនៅក្នុងលក្ខណៈភូមិសាស្ត្រផ្សេងៗគ្នាអាស្រ័យលើលទ្ធភាពដែលអ្នកភូមិអាចប្រើប្រាស់បាន ហើយភូមិថ្មីទាំងនោះក៏មានឈ្មោះខុសៗគ្នាផងដែរ ។ អ្នកភូមិមួយចំនួនបានផ្លាស់ពីភូមិចាស់នៅតាមដងទន្លេទៅរស់នៅក្នុងភូមិថ្មីដែលជាតំបន់ខ្ពស់ស្ថិតនៅតាមដងទន្លេដដែល និងអ្នកភូមិមួយចំនួនទៀតចាកចេញពីទន្លេទៅរស់នៅតំបន់ឆ្ងាយពីទន្លេ ( ចំងាយពី ៧ ដល់ ៣០ គីឡូមែតពីភូមិចាស់) ។ ចំពោះអ្នកភូមិដែលបានបោះបង់ និងផ្លាស់ប្តូរទីលំនៅទៅរស់នៅកន្លែងថ្មីនៅតែប្រើឈ្មោះភូមិចាស់ដដែល ដោយគ្រាន់តែថែមឈ្មោះតំបន់ថ្មីនោះតែប៉ុណ្ណោះ ។ ទោះបីជាភូមិដើមត្រូវបានបែងចែកជាពីរ ឬបីក្រុមក្តី ក៏នៅតែមានប្រធានភូមិម្នាក់សំរាប់គ្រប់គ្រងលើក្រុមផ្សេងៗ ដែលបែកចេញពីគ្នានោះដដែល ។

នៅចន្លោះឆ្នាំ ១៩៨១-១៩៩៦ ស្រុកអណ្តូងមាសមានឃុំចំនួន ២ និងភូមិចំនួន ១៦ តែប៉ុណ្ណោះដែលនៅតាម ដងទន្លេសេសាន ។ នៅឃុំញ៉ាងមានភូមិចំនួន ១១ រួមមានភូមិតាំងសេ ភូមិញ៉ាង ភូមិដាល ភូមិកេត ភូមិតាំងជិក ភូមិ ណាយ ភូមិកាជូត ភូមិមួយ ភូមិពែង ភូមិចាយ ភូមិតាង៉ា ។ នៅឃុំតាឡាវមានភូមិចំនួន ៥ រួមមាន ភូមិអ៊ុន ភូមិកាណាត ភូមិតាណង ភូមិតាឡាវ និងភូមិកាក់ ។

ចាប់តាំងពីឆ្នាំ ១៩៩៧ មកដល់ប្ចុប្បន្ននេះ ភូមិទាំងនោះមានការប្រែប្រួលយ៉ាងខ្លាំងដោយសារមានអ្នកភូមិជា ច្រើនបានចាកចេញពីទន្លេសេសានទៅរស់នៅតំបន់ភ្នំ និងតំបន់ខ្ពង់រាប គឺនៅក្រោយពេលមានទឹកជំនន់យ៉ាងធ្ងន់ធ្ងរនៅឆ្នាំ ១៩៩៦ និងក្រោយពេលអ្នកភូមិបានដឹងថាមានទំនប់វារីអគ្គិសនីយ៉ាលីនៅតំបន់ខ្សែទឹកខាងលើនៃទន្លេសេសានក្នុងប្រទេសវៀតណាម ។ មកដល់បច្ចុប្បន្ននេះ នៅក្នុងឃុំតាឡាវនៅ

សល់ភូមិចំនួន ៤ ( ភូមិតាណង ភូមិកាក់ ភូមិតាឡាវ និងភូមិអ៊ិន) និងក្រុមតូចចំនួន ១ ក្រុម ( របស់ភូមិ កាណាត) ហើយនៅឃុំញ៉ាងនៅសល់តែក្រុមតូចៗ ចំនួន ៦ ក្រុម ( ក្រុមតាំងបរខាំ ក្រុមតាំងកាទៃ ក្រុមតាំងម៉ាង ក្រុមដាលវាលលែង ក្រុមគែតវាលលែង និងក្រុមកាជូតទន្លេ) តែប៉ុណ្ណោះដែលរស់នៅតាមដងទន្លេ ។ សព្វថ្ងៃនេះ ក្រុមអ្នកភូមិដែលបន្តរស់នៅតាមដងទន្លេមានចំនួនតិចជាងក្រុមអ្នក ភូមិដែលបានចាកចេញ ។

ភូមិតាំងសេមានកំណើតតាំងពីយូរយាណាស់មកហើយ ហើយភូមិនេះត្រូវបានទទួលស្គាល់ជាផ្លូវការចាប់តាំង ពីឆ្នាំ១៩៨១ ។ ភូមិតាំងសេបានបែកចេញជាកូនភូមិតូចៗ តាមក្រុមចំនួន ៥ រួមមានក្រុមតាំងលោម ក្រុមតាំងម្លូ ក្រុម តាំងបខាំ ក្រុមតាំងម៉ាង និងក្រុមតាំងកាតៃ ។ ក្រុមតាំងលោម និងក្រុមតាំងម្លូស្ថិតនៅតំបន់ភ្នំភាគខាងជើង និងមាន ចំងាយប្រមាណ ១៥-២០ គីឡូម៉ែត្រ ពីទន្លេសេសាន ។ ចំណែកឯក្រុមតាំងបខាំ ក្រុមតាំងម៉ាង និង ក្រុមតាំងកាតៃ វិញ មានទីតាំងស្ថិតនៅតាមដងទន្លេដដែល ( ក្នុងចំណោមក្រុមទាំង៥ ខាងលើគឺបានធ្វើការសិក្សាតែ ២ ក្រុម ប៉ុណ្ណោះ) ។ ក្រុមអ្នកភូមិ តាំងលោមបានចាកចេញពីទន្លេនៅឆ្នាំ ១៩៩៩ ចំណែកឯភូមិតាំងម្លូវិញបានបែកចេញពីទន្លេ និងភូមិដើមនៅឆ្នាំ២០០៤ ។ អ្នកភូមិនៅក្រុមទាំងពីរជាជនជាតិដើមភាគតិចចារាយដែលមកដល់បច្ចុប្បន្ននេះ ភូមិតាំង លោមមាន ៧៣ គ្រួសារ និងចំនួន ប្រជាជនសរុប ៣៣២ នាក់ ក្នុងនោះមានស្ត្រីចំនួន ១៧៤ នាក់ ចំណែកឯភូមិតាំងម្លូ វិញមាន ៨៧ គ្រួសារ និងប្រជាជនសរុប ចំនួន ៤២០ នាក់ ក្នុងនោះមានស្ត្រី ២១៩ នាក់ ។ ភូមិកាជូតវិញក៏មាន កំណើតនៅតាមដងទន្លេសេសានតាំងពីយូរយារ ណាស់មកហើយ ហើយភូមិនេះត្រូវបានបែកចេញជាពីរក្រុម ដែលអ្នកភូមិហៅក្រុមនៅតាមដងទន្លេថា ភូមិកាជូតទន្លេ និងហៅក្រុមមួយទៀតដែលបែកចេញទៅតំបន់ភ្នំថា កាជូតភ្នំ ។ កាជូតភ្នំស្ថិតនៅលើតំបន់ភ្នំភាគខាងជើងទន្លេសេសសាន និងមានចំងាយប្រមាណ ១០គីឡូម៉ែត្រ ពីកាជូតទន្លេ ។ ប្រជា ជនភាគច្រើនដែលបានចាកចេញទៅរស់នៅភូមិកាជូតភ្នំ គឺ ជនជាតិកាចក់ ក្រៅពីនោះមានជនជាតិចារាយ និងទំពួន ខ្លះៗ ។ ភូមិកាជូតភ្នំបានចែកចេញពីទន្លេ នៅឆ្នាំ ១៩៩៩ ហើយមកដល់បច្ចុប្បន្នភូមិនេះមាន ៦២ គ្រួសារ ប្រជាជនសរុប ចំនួន ៣២៤ នាក់ ក្នុងនោះមានស្ត្រី ១៩៤ នាក់ ។ ឯ ភូមិដាលវិញក៏ជា ភូមិដែលមានវត្តមាននៅតាមដងទន្លេតាំងពីយូរ មកហើយ ។ ភូមិដាលបានចែកចេញជា ៣ ក្រុមតូចៗ ដែលអ្នកភូមិហៅ ឈ្មោះភូមិទាំងនោះថា ភូមិដាលព្ញ័រ ភូមិដាល ប៉ក់ និងភូមិដាលវាលលែង ។ ភូមិដាលព្ញ័របានបែកចេញពីទន្លេនៅឆ្នាំ១៩៩៧ ហើយស្ថិតនៅតំបន់អូរព្ញ័រលើភ្នំជី ដែលមានចំងាយប្រមាណ ៨ គីឡូម៉ែត្រ ពីទន្លេ ។ ឯភូមិ ដាលប៉ក់វិញទើបតែចាកចេញពីទន្លេនៅខែមិនា ឆ្នាំ២០០៦ ហើយស្ថិតនៅតំបន់អូរប៉ក់ ដែលមានចំងាយប្រមាណ ៤ គីឡូម៉ែត្រ ពីទន្លេ ។ ចំណែកឯភូមិ ដាលវាលលែងគឺស្ថិតនៅតាមដងទន្លេដដែល ។ ទោះបីជាភូមិដាលត្រូវបានបែកចេញជាបីភូមិតូចៗក្រៅផ្លូវការក្តីក៏នៅតែមានប្រធានភូមិតែមួយដដែល សំរាប់គ្រប់គ្រងភូមិធំរួមជាផ្លូវការ គឺភូមិដាល ។ មកដល់បច្ចុប្បន្ននេះ អ្នកភូមិដែលបានចាកចេញពីទន្លេសេសាននៅ ភូមិដាលព្ញ័រមាន៣៦គ្រួសារ ប្រជាជនសរុបចំនួន ១៥៨ នាក់ ក្នុងនោះមានស្ត្រីចំនួន៧៣នាក់ ហើយអ្នកភូមិជាជនជាតិដើមភាគតិចចារាយ ។ ឯភូមិដាលប៉ក់វិញមាន ៣៣ គ្រួសារ ប្រជាជនសរុបចំនួន ១៥៥នាក់ដែលនៅក្នុងនោះ មានស្ត្រី ចំនួន៨៧ នាក់ ហើយអ្នកភូមិជាជនជាតិដើមភាគតិចចារាយ ។

**ឃុំញ៉ាង :** មានភូមិញ៉ាង ភូមិតាំងជិក និងភូមិណាយ បានបោះបង់និងផ្លាស់ប្តូរទីលំនៅពីភូមិចាស់នៅតាមដងទន្លេ ក្នុងរូបភាពរើភូមិទាំងមូលតែម្តង ។ អ្នកភូមិ ចាស់ទុំភូមិ និងប្រធានភូមិបានព្រមព្រៀងគ្នារើភូមិរបស់ខ្លួនតាម ការប្រជុំពិភាក្សានៅក្នុងភូមិ ។ ភូមិញ៉ាងបានចាកចេញពីទន្លេនៅខែ មករា ឆ្នាំ ១៩៩៩ ហើយនាំគ្នាទៅរស់នៅតំបន់ភ្នំ នៅភាគខាងជើងទន្លេសេសានចំងាយប្រមាណ ៣០ គីឡូម៉ែត្រ ។ ប្រជាជននៅភូមិញ៉ាងជាជនជាតិដើមភាគតិចចារាយ ហើយមកដល់ ពេលបច្ចុប្បន្ន ភូមិនេះមាន ៤៣ គ្រួសារ ប្រជាជនសរុបចំនួន ១៩៥ នាក់

ក្នុងនោះមានស្ត្រីចំនួន ៩៧នាក់ ។ ចំណែកឯភូមិ តាំងជិកវិញបានចាកចេញពីទន្លេសេសាននៅឆ្នាំ ១៩៩៧ ផងដែរ ។ អ្នកភូមិតាំងជិកបានរើភូមិទៅរស់នៅតំបន់ភ្នំដែលមានចំងាយប្រមាណ ៣០ គីឡូម៉ែត្រ ពីទន្លេ ។ អ្នកភូមិទាំងនោះជាជនជាតិដើមភាគតិចចារាយ ហើយ មកដល់បច្ចុប្បន្ននេះ ភូមិតាំងជិកមាន៥៣គ្រួសារ ចំនួនប្រជាជនសរុប៣៥៣នាក់ ក្នុងនោះមានស្ត្រីចំនួន១៣០ នាក់ ។ ដោយឡែកភូមិណាយក៏ជាភូមិមួយដែលធ្លាប់ស្ថិតនៅតាមដងទន្លេសេសានក្នុងរយៈពេលមួយយ៉ាងយូរដូចភូមិញ៉ាង និងភូមិតាំងជិកផង ដែរ ហើយភូមិនេះបានចាកចេញពីទន្លេនៅ ខែ មករា ឆ្នាំ ១៩៩៧ ដូចភូមិទាំងពីរដែរ ។ ប្រជាជន ភូមិណាយបានបោះបង់ និងផ្លាស់ប្តូរទីលំនៅពីភូមិចាស់ទៅរស់នៅលើតំបន់ភ្នំនៅភាគខាងជើងទន្លេដែលមានចំងាយ ប្រហែល ១៥ គីឡូម៉ែត្រ ពីទន្លេ ។ អ្នកភូមិណាយជាជនជាតិដើមភាគតិចចារាយ ហើយមកដល់ពេលនេះភូមិណាយ មាន៦២គ្រួសារ ចំនួនប្រជាជន សរុប ២៨៧ នាក់ ក្នុងនោះមានស្ត្រីចំនួន ១៣៧ នាក់ ។ ប្រជាជនភូមិទាំងនេះជាទូទៅធ្វើចំការដាំស្រូវបន្លែ និងដំណាំ ស្វាយចន្ទី ហើយទន្ទឹមនឹងនោះ អ្នកភូមិក៏ចិញ្ចឹមសត្វមួយចំនួន ដូចជា មាន់ ជ្រូក គោ និងក្របីជាដើម ។

**ឃុំតាឡាវ :** ជាឃុំទីពីរនៅខ្សែទឹកខាងក្រោមនៃស្រុកអណ្តូងមាស មានភូមិចំនួន២ ដែលត្រូវបានជ្រើសរើស យកមកធ្វើការសិក្សា ហើយលទ្ធផលអាចឆ្លុះបញ្ចាំងទៅលើភូមិដទៃទៀតក្នុងចំណោម ៥ ភូមិ ដែលបានផ្លាស់ប្តូរ ។ ភូមិទាំងពីរ នោះគឺភូមិកាណាត និងភូមិតាណងដែលប្រជាជនក្នុងភូមិភាគច្រើនជាជនជាតិដើមភាគតិចកាចក់ ចំណែកឯជនជាតិ ផ្សេងទៀតមានចារាយ ទំពួន និងឡាវ ។ ប្រភេទនៃការចាកចេញពីទន្លេរបស់ភូមិទាំងពីរគឺខុសគ្នា ។ ភូមិកាណាតមាន ប្រជាជន ១ ក្រុម ចាកចេញពីទន្លេទៅនៅតំបន់ភ្នំ ចំណែកឯភូមិមួយក្រុមទៀតនៅរស់នៅតាមតំបន់ខ្ពង់រាបនៃដងទន្លេ សេសានដដែល ។ ប៉ុន្តែភូមិតាណងវិញត្រូវបានប្រជាជនរើផ្លាស់ប្តូរទីតាំងភូមិទាំងអស់តែម្តង ហើយទៅរស់នៅកន្លែងថ្មី ដែលជាតំបន់ខ្ពស់ដែលមានចំងាយប្រមាណជា៥០០ម៉ែត្រ ភាគខាងជើងនៃទន្លេ ។ ភូមិនេះ ត្រូវ បានរើទៅកាន់តំបន់ថ្មីនៅក្នុងឆ្នាំ ២០០០ ភាគច្រើនជាជនជាតិដើមភាគតិចកាចក់ និងជនជាតិមួយចំនួនទៀតមាន ចារាយ ទំពួន និងឡាវ ។ បច្ចុប្បន្ននេះមានប្រជាជន ៥២ គ្រួសារ មនុស្សសរុបចំនួន ២២៥ នាក់ ក្នុងនោះមានស្ត្រីចំនួន ១២៥ នាក់ ។

ប្រជាជនភូមិកាណាតមួយក្រុមធំបានចាកចេញពីទន្លេទៅរស់នៅតំបន់ខ្ពង់រាបតាមជើងភ្នំដែលមានឈ្មោះថា( **ទួល បានតាឌិនដែង**) ភាគ បខាងត្បូង ហើយដែលមានចំងាយប្រហែល ៨ គីឡូម៉ែត្រ ពីទន្លេ ដោយដាក់ឈ្មោះភូមិថ្មីថា ភូមិកា ណាតធំ ឬភូមិទៃសកាណាតអន្ទោះ ( ជាភាសារជនជាតិកាចក់) ។ ចំណែកឯក្រុម ១ ទៀត ដែលបែក តែរស់ នៅជាប់ទន្លេ ហៅថា ភូមិកាណាតតូច ។ អ្នកភូមិបានចាកចេញពីទន្លេទៅរស់នៅតំបន់ថ្មីនោះដោយប្រើរយៈពេលពីរឆ្នាំ គឺចាប់ពីឆ្នាំ ១៩៩៧-១៩៩៨ ទើបសំរេចចិត្តបោះបង់ភូមិចាស់ចោលទាំងស្រុង ហើយអ្នកភូមិទាំងនោះភាគច្រើនជាជនជាតិដើមភាគតិច កាចក់ និងមានជនជាតិភាគតិចមួយចំនួនទៀតដូចជា ចារាយ ទំពួន និងគ្រឹងៗខ្លះដែរ ។ បច្ចុប្បន្ននេះ ភូមិកាណាតធំមាន ចំនួន ៩៤ គ្រួសារ ប្រជាជនសរុបចំនួន ៥៥១ នាក់ ក្នុងនោះមានស្ត្រីចំនួន ២៤៥ នាក់ ។

យោងតាមលទ្ធផលសិក្សាខាងលើ យើងរកឃើញថាមានភូមិថ្មីចំនួន ១០ ដែលបានកើតឡើង ពីការបោះបង់ និងផ្លាស់ប្តូរទីលំនៅពីភូមិចាស់ ។ ភូមិទាំង ១០ នោះ មានដូចជា ភូមិញ៉ាង ភូមិតាំងម្លូ ភូមិតាំងលោម ភូមិដាលព្វ័រ ភូមិដាលប៉ក់ ភូមិតាំងជិក ភូមិណាយ ភូមិកាជូតភ្នំ នៅក្នុងឃុំញ៉ាង និងភូមិតាណង និងភូមិកាណាតធំនៅក្នុង ឃុំ តាឡាវ ។ ភូមិដែលបែកជាកូនភូមិតូចៗ ទាំងនេះជាឈ្មោះភូមិដែលប្រជាជនហៅក្រៅផ្លូវការ ហើយមិនទាន់មានការទទួលស្គាល់ជាផ្លូវការនៅឡើយ ។ ចំពោះស្ថិតិប្រជាជនភូមិ និងឃុំ គេប្រើប្រាស់ឈ្មោះភូមិដើមតែមួយ ។ ដោយយោង តាមស្ថិតិប្រជាជន ភូមិ និងឃុំ ព្រមទាំងការចុះទៅសម្ភាសផ្ទាល់ ក្រុមសិក្សាស្រាវជ្រាវបានរកឃើញថា មានប្រជាជន ចំនួន ៥៩៤ គ្រួសារ ដែលមានសមាជិកសរុបចំនួន ២,៩០០ នាក់ ក្នុងនោះមានស្ត្រីចំនួន ១,៤៨១ នាក់ បានចាកចេញពី ទន្លេទៅរស់នៅតំបន់ភ្នំ

និងតំបន់ខ្ពង់រាបឆ្ងាយៗ ។ ក្រុមសិក្សាក៏បានរកឃើញថាមានប្រជាជនចំនួន ៣១៦ គ្រួសារ និង មានសមាជិកសរុបចំនួន ១,៦៦៤ នាក់ ក្នុងនោះមានស្ត្រីចំនួន ៨៨២ នាក់ កំពុងរស់នៅតាមដងទន្លេសេសាននៅក្នុងស្រុកអណ្តូងមាស ។

**-ស្រុកតាវែង :** វាជាស្រុកមួយដែលនៅជាប់ស្រុកអណ្តូងមាសផ្នែកខ្សែទឹកខាងលើ និងជាប់ស្រុកវើនសៃនៅផ្នែក ខ្សែទឹកខាងក្រោម ។ ស្រុកតាវែងមានឃុំចំនួន ២ គឺឃុំតាវែងលើ និងឃុំតាវែងក្រោម ។ មានភូមិចំនួន១០ នៅ ឃុំ តាវែងលើ និងភូមិ ១០ ទៀត នៅឃុំតាវែងក្រោមដែលស្ថិតនៅតាមដងទន្លេសេសានមុនឆ្នាំ ២០០១ ។ ចាប់ពីឆ្នាំ ២០០១ មកដល់បច្ចុប្បន្នមានតែភូមិចំនួន ៩ នៅឃុំតាវែងក្រោមដែលស្ថិតនៅតាមដងទន្លេ ពីព្រោះមានភូមិចំនួន ១ បានរើទីកន្លែង ថ្មីនៅកាន់តំបន់ខ្ពង់រាបឆ្ងាយពីមាត់ទន្លេឈ្មោះថា ភូមិទុន ។ ប្រជាជនភាគច្រើនដែលកំពុងរស់នៅក្នុងឃុំ ទាំងពីរតាមដងទន្លេ គឺជាជនជាតិដើមភាគតិចព្រៅ ហើយក៏មានជនជាតិគ្រឹង ឡាវ និងខ្មែរមួយចំនួនតូចរស់នៅទីនោះ ផងដែរ ។ អ្នកភូមិតាម ដងទន្លេជាទូទៅប្រកបរបរចិញ្ចឹមជីវិតដោយធ្វើស្រែនៅតាមដីវាលទំនាប និងធ្វើចំការនៅតាមដីទីទួល និងខ្ពង់រាប ។

នៅស្រុកតាវែងប្រជាជនចាកចេញទីទន្លេក្នុងរូបភាពរើភូមិទាំងមូលតែម្តង ។ ភូមិដែលត្រូវបានប្រជាជនផ្លាស់ប្តូរ ទីលំនៅពីភូមិចាស់ពីទន្លេនោះគឺ ភូមិកិគួងក្រោម នៅឃុំតាវែងក្រោម ។ ភូមិនេះបានរើចេញពីមាត់ទន្លេ ទៅតំបន់ខ្ពង់រាប មួយមានចំងាយប្រមាណ ៤០០ ម៉ែត្រពីទន្លេប៉ុណ្ណោះ ។ ទីតាំងភូមិថ្មីនៅទីនោះជាដីទួលខ្ពស់ជាងទីតាំងភូមិ ចាស់ ដែលជាដីទាបត្រូវបានទឹកទន្លេលិចយ៉ាងញឹកញាប់ ។ អ្នកភូមិបានរើភូមិនោះក្នុងឆ្នាំ ២០០១ ដោយអ្នកភូមិ បាន រៀបចំផ្ទះ និង សំភារៈសំរាប់ចាកចេញតាំងពីចុងឆ្នាំ ២០០០ មកម្លេះ ។ អ្នកភូមិទាំងនោះជាជនជាតិដើមភាគតិចព្រៅ ដែលមកដល់ពេលនេះភូមិកិគួងក្រោមមាន ២២គ្រួសារ ប្រជាជនសរុបចំនួន៩៨នាក់ ក្នុងនោះមានស្ត្រីចំនួន ៤៦នាក់ ។

ដូចនេះនៅស្រុកតាវែងមានជនជាតិព្រៅចំនួន ២២ គ្រួសារ ដែលមានសមាជិកសរុបចំនួន ៩៨ នាក់ ក្នុងនោះ មាន ស្ត្រីចំនួន ៤៦ នាក់ បានរើភូមិចេញពីទន្លេសេសាន ។ ហើយនៅបច្ចុប្បន្ននេះមានប្រជាជន ១,១៨៦គ្រួសារ ស្មើនឹង ៥,២៥២ នាក់ ក្នុងនោះមានស្ត្រីចំនួន ២,៧១៣ នាក់ នៅក្នុងភូមិចំនួន១៩ និងឃុំចំនួន២ ដែលកំពុងរស់នៅតាមដង ទន្លេសេសាន ក្នុងស្រុកតាវែង ។

**-ស្រុកវើនសៃ :** វាជាស្រុកដែលស្ថិតនៅតាមតំបន់ខ្សែទឹកក្រោមគេបំផុងក្នុងចំណោមស្រុកទាំង៤នៅតាម ដងទន្លេ សេសានក្នុងខេត្តរតនគិរី ។ មានឃុំចំនួន៩ និងមានភូមិចំនួន២៦ នៃស្រុកវើនសៃដែលស្ថិតនៅតាមដងទន្លេ សេសាន ។ ស្រុកវើនសៃមានប្រជាជនរស់នៅតាមដងទន្លេសេសានច្រើនជាងស្រុកផ្សេងៗទៀតនៅក្នុងខេត្តរតនគិរី ហើយមានប្រជាជនរស់នៅចំរុះជនជាតិ និងវប្បធម៌ ដូចជាជនជាតិដើមភាគតិចទាំងនោះរួមមាន ទំពួន គ្រឹង កាចក់ កាវ៉ែត ព្រៅ លុន ហើយនិងមានជនជាតិ ឡាវ ចិន ខ្មែរផងដែរ ដែលអ្នកស្រុករស់នៅពឹងអាស្រ័យលើទន្លេសេសាន តាំងពីដូនតាមកម្លេះ ។

ការបោះបង់ និងផ្លាស់ប្តូរទីលំនៅពីភូមិចាស់ទៅរស់នៅតំបន់ថ្មីរបស់អ្នកភូមិដែលរស់នៅតាមដងទន្លេសេសាន នៅ ស្រុកវើនសៃមានលក្ខណៈខុសពីការចាកចេញរបស់អ្នកភូមិនៅស្រុកតាវែង និងអណ្តូងមាស ។ នៅស្រុកវើនសៃ អ្នក ភូមិបោះបង់ និងផ្លាស់ប្តូរទីលំនៅពីភូមិចាស់ទៅរស់នៅតំបន់ថ្មីក្នុងរូបភាពជាក្រុមតូចៗ ដោយប្រើរយៈពេលពី ១-៤ ឆ្នាំ ប៉ុន្តែយើង ឃើញមានភូមិខ្លះចាកចេញតែក្នុងរយៈពេល១ឆ្នាំប៉ុណ្ណោះ ។ ស្រុកនេះពុំមានការចាកចេញពីទន្លេសេសាន ដោយរើភូមិ ទាំងមូលនោះទេ គឺគ្រាន់តែចេញពីភូមិដើមជាក្រុមតូចៗ ទៅរស់នៅតាមតំបន់ខ្ពង់រាបនិងតំបន់ភ្នំដែល អាចផ្តល់លទ្ធភាព បង្កបង្កើនផលស្រែចំការសមស្របសំរាប់អ្នកភូមិ ។ ស្រុកវើនសៃមានប្រជាជនបោះបង់និងផ្លាស់ប្តូរទីលំនៅពីភូមិចាស់ នៅតាមដងទន្លេសេសានចំនួន ៥ ភូមិនៅក្នុងឃុំចំនួន ៤ ហើយអ្នកភូមិភាគច្រើនជាជនជាតិដើម ភាគតិច

ចំណែកឯជនជាតិ មួយចំនួនទៀតនោះគឺជនជាតិឡាវ ។ ភូមិ និងឃុំទាំងនោះរួមមាន ភូមិប៉ាតឹង ឃុំកោះប៉ង ភូមិផាក់ណាម និងភូមិ ឃួន ឃុំកោះពាក ភូមិកាចូនក្រោម ឃុំកាចូន និងភូមិបានប៉ុង ឃុំបានប៉ុង ។

ប៉ាតឹងជាភូមិជនជាតិដើមភាគតិចព្រៅ កាវែត និងភ្នង ហើយស្ថិតនៅក្នុងឃុំកោះប៉ង់ដែលជាតំបន់ខ្សែទឹកលើគេបើប្រៀបធៀបទៅនឹងឃុំផ្សេងៗទៀត ។ ឃុំនេះមានព្រំប្រទល់ជាប់នឹងឃុំតាវែងក្រោមនៃស្រុកតាវែងនៅផ្នែក ខាងលើ និងជាប់ឃុំកោះពាកនៅផ្នែកខាងក្រោម ។ អ្នកភូមិប៉ាតឹងបានចាកចេញពីភូមិដើមតាមដងទន្លេសេសានទៅ រស់នៅតំបន់ថ្មីពាកន្លែងផ្សេងៗគ្នា គឺស្រែតាំងឡាវ អូរប៉ង់ និងអូរកាញ់ជ្រី ។ ទោះបីជាផ្លាស់ទៅរស់នៅតំបន់ថ្មីក្តី ក៏អ្នក ភូមិទាំងនោះនៅតែ ចិញ្ចឹមសត្វស្រុកមួយចំនួនដូចជា មាន់ ជ្រូក គោ និងក្របី ដែលជាទ្រព្យសម្បត្តិដ៏សំខាន់សំរាប់អ្នក ភូមិ ។ អ្នកភូមិបានចាប់ ផ្តើមបោះបង់ និងផ្លាស់ប្តូរទីលំនៅពីភូមិចាស់ទៅរស់នៅតំបន់ថ្មីតាំងពីឆ្នាំ ២០០២ ដល់ ឆ្នាំ ២០០៥ ដោយចាប់ចាកចេញ ពីភូមិដំបូងតែពីរបីគ្រួសារប៉ុណ្ណោះ ហើយឆ្នាំក្រោយៗមកមានគ្រួសារផ្សេងៗទៀតនៅ ក្នុងភូមិចាកចេញតាម ។ មានអ្នក ភូមិជនជាតិព្រៅតែ ២គ្រួសារ ដែលមានសមាជិកសរុប ៧ នាក់ ក្នុងនោះមានស្ត្រី ៣ នាក់ រស់នៅតំបន់អូរកាញ់ជ្រី ដែល ជាតំបន់ឆ្ងាយពីទន្លេជាងគេ បើប្រៀបធៀបទៅនឹងតំបន់អូរប៉ង់ និងតំបន់ស្រែតាំងឡាវ ។ នៅតំបន់អូរប៉ង់មានអ្នកភូមិ ជនជាតិព្រៅចំនួន ៧ គ្រួសារ ដែលមានសមាជិកសរុប ៧៨ នាក់ ក្នុងនោះមានស្ត្រី ចំនួន ៤០ នាក់ កំពុងរស់នៅចាប់ផ្តើម ពីឆ្នាំ ២០០២ មក ។ ចំណែកតំបន់ស្រែតាំងឡាវវិញមានប្រជាជនចំនួន៦គ្រួសារ ដែលមាន សមាជិកសរុប ៣៩ នាក់ ក្នុងនោះមានស្ត្រី ១៦ នាក់ ហើយអ្នកភូមិជាជនជាតិព្រៅដែលបានមករស់នៅទី នេះតាំងពីឆ្នាំ ២០០២ ដែរ ។ ដូចនេះនៅភូមិប៉ាតឹងមានប្រជាជនចាកចេញពីទន្លេចំនួន ១៧ គ្រួសារ ដែលមានសមាជិក សរុប ១២៤ នាក់ ក្នុងនោះមានស្ត្រីចំនួន ៥៩ នាក់ ដែលជាជនជាតិដើមភាគតិចព្រៅ ។

នៅឃុំកោះពាកមាន ២ ភូមិ គឺភូមិផាក់ណាម និងភូមិឃួនដែលមានប្រជាជនបោះបង់ និងផ្លាស់ប្តូរទីលំនៅពី ភូមិចាស់ទៅរស់នៅតំបន់ថ្មីឆ្ងាយពីទន្លេ ។ ប្រជាជននៅភូមិផាក់ណាម និងភូមិឃួនជាជនជាតិដើមភាគតិចគ្រឹង ដែល បានរស់នៅទីនេះយូរណាស់មកហើយ ។ អ្នកភូមិប្រកបរបរចិញ្ចឹមជីវិតដោយការធ្វើស្រែ និងចំការជាចំបង និងចិញ្ចឹម សត្វស្រុកមួយ ចំនួនទៀតដូចជា មាន់ ជ្រូក គោ និងក្របី ។ ប្រជាជននៅភូមិផាក់ណាមបានចាប់ផ្តើមចាកចេញពីទន្លេ សេសាន ចាប់តាំង ពីឆ្នាំ ១៩៩៨ ដល់ ឆ្នាំ ២០០៣ ។ នៅឆ្នាំដំបូង មានតែគ្រួសារមួយចំនួនប៉ុណ្ណោះ ។ មកដល់បច្ចុប្បន្ន នេះ មានគ្រួសារចំនួន៥៨ និងប្រជាជនសរុប ២២៨ នាក់ ក្នុងនោះមានស្ត្រីចំនួន ១២៥ នាក់ ។ អ្នកភូមិបានទៅរស់នៅ តំបន់អូរឆ្នាំងដែលជាតំបន់ភ្នំ តំបន់ថ្មីនេះស្ថិតនៅភាគខាងត្បូងទន្លេប្រហែល ៥ គីឡូម៉ែត្រ ។ ចំណែកឯភូមិឃួនវិញមាន ប្រជាជនចំនួន ៧ គ្រួសារ ដែល មានសមាជិកសរុប ៣២ នាក់ ក្នុងនោះមានស្ត្រី ១៩ នាក់ បានចាកចេញពីទន្លេទៅរស់ នៅតំបនភ្នំនៅឆ្នាំ ២០០០ ។ តំបន់ថ្មី ដែលអ្នកភូមិរស់នៅមានឈ្មោះថា ច្រប់ចាឡ ដែលស្ថិតនៅភាគខាងត្បូងទន្លេ ប្រហែល ១០ គីឡូម៉ែត្រ ។ ហើយអ្នកភូមិ ប្រកបរបរចិញ្ចឹមជីវិតដោយការធ្វើចំការជាចំបង ប៉ុន្តែទទ្ទឹមនឹងនោះក៏មាន អ្នកភូមិខ្លះធ្វើស្រែផងដែរ ។

យោងតាមការសិក្សាខាងលើ យើងរកឃើញថា នៅឃុំកោះពាកមានអ្នកភូមិចំនួន ៦៥ គ្រួសារ ដែលមាន សមាជិកសរុប ២៦០ នាក់ ក្នុងនោះមានស្ត្រី ១៤៤ នាក់ បានចាកចេញពីទន្លេទៅរស់នៅតំបន់ភ្នំ ។

ឃុំកាចូនស្ថិតនៅប្រមាណជា១០គីឡូម៉ែត្រពីទីរួមស្រុកវីនសៃ ហើយមានព្រំប្រទល់ជាប់ឃុំកោះពាកនៅផ្នែក ខាងលើ និងជាប់ឃុំប៉ង់នៅផ្នែកខាងក្រោម។ នៅឃុំនេះមានតែភូមិ ០១ ទេដែលមានប្រជាជនបោះបង់ និងផ្លាស់ប្តូរ ទីលំនៅពីភូមិចាស់ទៅរស់នៅតំបន់ថ្មីឆ្ងាយពីទន្លេ។ នោះគឺជាភូមិកាចូនក្រោម ដែលដំបូងឡើយមានអ្នកភូមិតែ ៥ គ្រួសារ ប៉ុណ្ណោះដែលបានចាកចេញទន្លេនៅឆ្នាំ ២០០១ ហើយមកដល់បច្ចុប្បន្ននេះមានអ្នកភូមិចាកចេញតាមជា បន្តបន្ទាប់រហូតដល់ទៅ ១០ គ្រួសារ ដែលមានប្រជាជនសរុប ៧៥ នាក់ ក្នុងនោះមានស្ត្រីចំនួន ២៥នាក់។ ក្នុងចំណោម ប្រជាជនទាំងនោះមាន ជនជាតិដើមភាគតិចទំពួន និងឡាវ។

បានប៉ុងជាភូមិមួយនៅក្នុងឃុំបានប៉ុង ដែលមានប្រជាជនបោះបង់ និងផ្លាស់ប្តូរទីលំនៅពីភូមិចាស់ពីទន្លេទៅ រស់នៅ តំបន់ព្រៃភ្នំ។ ប្រជាជននៅភូមិបានប៉ុងភាគច្រើនជាជនជាតិឡាវ និងមានជនជាតិខ្មែរមួយចំនួនតូច។ ជនជាតិ ឡាវនៅភូមិនេះប្រកបរបរចិញ្ចឹមជីវិតដោយការធ្វើស្រែជាចំបង ប៉ុន្តែអ្នកភូមិខ្លះក៏ធ្វើចំការផងដែរ។ អ្នកភូមិបានចាក ចេញពីទន្លេទៅរស់នៅតំបន់ខ្ពស់មួយដែលមានឈ្មោះថា ត្រពាំងញ៉ាពៃ នៅឆ្នាំ ២០០០។ មកដល់បច្ចុប្បន្ននេះតំបន់ ត្រពាំងញ៉ាពៃមានអ្នក ភូមិរស់នៅចំនួន ១០ គ្រួសារ ដែលមានសមាជិក ៧៣ នាក់ ក្នុងនោះមានស្ត្រីចំនួន ៣៧ នាក់។ អ្នកភូមិដែលកំពុងរស់នៅ តំបន់ថ្មីនេះ គឺជាជនជាតិឡាវ។ ត្រពាំងញ៉ាពៃជាតំបន់ទួលខ្ពស់ ដែលស្ថិតនៅភាគខាងត្បូង ទន្លេប្រមាន ១០ គីឡូម៉ែត្រ។

ក្រុមសិក្សាស្រាវជ្រាវរកឃើញថានៅស្រុកវីនសៃមានភូមិចំនួន ៥ នៅក្នុងឃុំចំនួន ៤ ដែលមានប្រជាជនចំនួន ១០២ គ្រួសារ សមាជិកសរុប ៥៣២ នាក់ ក្នុងនោះមានស្ត្រី ២៦៥ នាក់ បានចាកចេញពីទន្លេទៅរស់នៅតាមតំបន់ ខ្ពង់រាប និងតំបន់ភ្នំ។ អ្នកភូមិទាំងនោះភាគច្រើនជាជនជាតិដើមភាគតិចគ្រឹង ព្រៅ ទំពួន ចារាយ ភ្នង និងកាវែត ហើយចំនួនតូច ជាជនជាតិឡាវ។ ក្នុងចំណោមជនជាតិដើមភាគតិចទាំងនោះ យើងឃើញថាជនជាតិគ្រឹងមានចំនួន ច្រើនជាងគេ ចំណែកឯជនជាតិឡាវវិញក៏មានតិចតួចដែរ ហើយអ្នកភូមិរស់នៅតំបន់ថ្មីពីរគឺ តំបន់ត្រពាំងញ៉ាពៃ និង តំបន់អូរតាម៉ៅ ដែលមកពីភូមិ បានប៉ុង និងភូមិកាចូនក្រោម។

ដោយយោងទៅតាមស្ថិតិភូមិ ឃុំ និងការចុះទៅសិក្សាជាក់ស្តែងផងបានរកឃើញថា សព្វថ្ងៃនេះ គេឃើញ មានប្រជាជន ចំនួន ២,៣៣៧ គ្រួសារ ដែលមានសមាជិកសរុប ១២,០៤៦ នាក់ ក្នុងនោះមានស្ត្រី ៦,១០៨ នាក់ កំពុង រស់នៅក្នុង ២៦ ភូមិ ៩ ឃុំ នៅស្រុកវីនសៃ។ ការសិក្សានេះបានរកឃើញថាក្នុងចំណោមប្រជាជនទាំងអស់ក្នុងស្រុកវីនសៃមានជនជាតិដើមភាគតិចរស់នៅតាមដងទន្លេច្រើនជាងជនជាតិផ្សេងៗ ទៀត។

**តារាងទី ៣ : ចំនួនប្រជាជនបោះបង់ទីលំនៅតាមស្រុកនិមួយៗ**

| ល.រ | ភូមិ | ឃុំ | ចំនួនគ្រួសារ | ចំនួនមនុស្ស | ស្ត្រី | ឆ្នាំចាកចេញ | តំបន់រស់នៅថ្មី |
|---|---|---|---|---|---|---|---|
| **ស្រុកអូរយាដាវ** | | | | | | | |
| ១ | ភិ | សេសាន | ៤ | ១៥ | ៨ | ២០០៣ | អូរត្រាវ អូរផ្លា |
| **ស្រុកអណ្តូងមាស** | | | | | | | |
| ២ | ញ៉ាង | ញ៉ាង | ៤៣ | ១៩៥ | ៩៧ | ១៩៩៧ | ញ៉ាង |
| ៣ | ដាល | ញ៉ាង | ៣៦ | ១៥៨ | ៧៣ | ១៩៩៧ | ដាលព័រ |
| | | ញ៉ាង | ៣៣ | ១៩៥ | ៨៧ | ២០០៦ | ដាលប៉ក់ |
| ៤ | តាំងសេ | ញ៉ាង | ៨៧ | ៤២០ | ២១៩ | ២០០៥ | តាំងមួ |
| | | ញ៉ាង | ៧៣ | ៣៣២ | ១៧៤ | ១៩៩៩ | តាំងលោម |
| ៥ | តាំងជិក | ញ៉ាង | ៥៣ | ២៥៣ | ១៣០ | ១៩៩៧ | តាំងជិក |
| ៦ | ណាយ | ញ៉ាង | ៦២ | ២៨៧ | ១៣៧ | ១៩៩៧ | ណាយ |
| ៧ | កាជូត | ញ៉ាង | ៦២ | ៣២៤ | ១៩៤ | ១៩៩៩ | កាជូតលើ |
| ៨ | កាណាតធំ | តាឡាវ | ៩៤ | ៥៥១ | ២៤៥ | ១៩៩៧-១៩៩៨ | កាណាតធំ |
| ៩ | តាណង | តាឡាវ | ៥១ | ២២៥ | ១២៥ | ២០០០ | តាណង |
| **ស្រុកតាវែង** | | | | | | | |
| ១០ | កិគួងក្រោម | តាវែងក្រោម | ២២ | ៩៨ | ៤៦ | ២០០១ | កិគួងក្រោម |
| **ស្រុកវើនសៃ** | | | | | | | |
| ១១ | ផាក់ណាម | កោះពាក | ៥៨ | ២២៨ | ១២៥ | ១៩៩៨-២០០៣ | អូរឆ្នាំង |
| ១២ | ឃួន | កោះពាក | ៧ | ២៤ | ២១ | ២០០០ | ច្រប់ចឡ |
| ១៣ | ប៉ាតឹង | កោះប៉ង់ | ២ | ៧ | ៣ | ២០០២-២០០៥ | អូរកាញ់ជ្រី |
| | | កោះប៉ង់ | ៦ | ៣៩ | ១៦ | ២០០២-២០០៥ | ស្រែតាំងឡាវ |
| | | កោះប៉ង់ | ៩ | ៧៨ | ៤០ | ២០០២-២០០៥ | អូរប៉ង់ |
| ១៤ | កាចូនក្រោម | ឃុំកាចូន | ១០ | ៧៥ | ២៥ | ២០០១-២០០៣ | អូរតាម៉ៅ |
| ១៥ | បានប៉ុង | បានប៉ុង | ១០ | ៧៣ | ៣៧ | ២០០០ | ត្រពាំងញ៉ាពៃ |
| **សរុប** | **១៥ ភូមិចាស់** | **៨ឃុំ** | **៧២២គ្រួសារ** | **៣,៥៤៥ នាក់** | **១,៨០០ នាក់** | **១៩៩៧-២០០៦** | **២០តំបន់ ឬភូមិថ្មី** |

## ៥.២ មូលហេតុនៃការចាកចេញពីទន្លេសេសាន

យើងសង្កេតឃើញថា ប្រជាជនតាមដងទន្លេសេសាននៃស្រុកទាំង ៤ ដូចជាស្រុកអូរយ៉ាដាវ ស្រុកអណ្ដូងមាស ស្រុកតាវែង និងស្រុកវើនសៃ ក្នុងខេត្តរតនគិរី បានបោះបង់ទីលំនៅចាស់តាមដងទន្លេសេសានដោយមានមូលហេតុចំនួន ៤ សំខាន់ៗ ។ មូលហេតុទាំងនោះរួមមាន :

- ទឹកជំនន់ញឹកញាប់
- បញ្ហាសន្តិសុខស្បៀង
- ខ្លាចទំនប់បាក់
- ចង់បានចំការថ្មី និងចង់ការពារដីកុំអោយអ្នកខាងក្រៅចាប់យក

### ៥.២.១ ទឹកជំនន់ញឹកញាប់

ក្រុមសិក្សាបានរកឃើញថា មានជនជាតិដើមភាគតិចចារាយ ៤ គ្រួសារដែលមានសមាជិក ១៥ នាក់ ស្ត្រី ៨ នាក់ នៅភូមិភិ ឃុំសេសាន ស្រុកអូរយ៉ាដាវបានបោះបង់ទីលំនៅរបស់ខ្លួនដោយមូលហេតុសំខាន់បំផុតគឺ ទឹកជំនន់លិច ស្រែ និងចំការញឹកញាប់ ។ ក្រុមសិក្សាទទួលបានព័ត៌មាននេះពីប្រធានភូមិ និងប្រជាជនមួយចំនួនទៀតដែលបានដឹង អំពីការសំរេចចិត្តរបស់អ្នកភូមិច្បាស់លាស់ (ការរកឃើញមូលហេតុនេះក្រុមសិក្សាមិនបាន សម្ភាសអ្នកបោះបង់ទីលំនៅផ្ទាល់ទេ ដោយសារតំបន់ដែលគាត់ទៅរស់នៅឆ្ងាយពីភូមិ និងមិនអាចធ្វើដំណើរដោយដើរបាននៅ រដូវវស្សា) ។


វាលស្រែដែលត្រូវបំផ្លាញដោយទឹកជំនន់

ដោយសារទឹកទន្លេឡើងចុះមិនទៀងទាត់ អ្នកភូមិដែលរស់នៅតាមដងទន្លេសេសានក្នុងស្រុកអណ្ដូងមាសភ័យខ្លាចកូនគាត់មានគ្រោះថ្នាក់ពេលទៅងូតទឹកដោយឥតមានចាស់ៗ នៅជាមួយ ។ អ្នកភូមិបាន បញ្ជាក់ប្រាប់យ៉ាងច្បាស់ថា ពីមុនមកយើងមិនដែលគិតគូពីចំណុចនេះទេ ប៉ុន្តែឥឡូវយើងត្រូវតែគិតដោយខានមិនបាន ពីព្រោះទឹកទន្លេសេសានយើងពេលនេះមិនអាចជឿទុកចិត្តបានដូចកាលពីមុនឡើយ ។

នៅស្រុកអណ្ដូងមាសការពិភាក្សាជាក្រុមរបស់អ្នកភូមិនៅភូមិកាជូត ភូមិញ៉ាង ភូមិតាំងជិក និងភូមិដាលប៉ក់ (ឈ្មោះផ្លូវការ "ភូមិដាល") បានកំណត់ការជន់លិចស្រែចំការ និងផ្ទះសំបែងតាមដងទន្លេសេសានជាមូលហេតុសំខាន់ ទី ២ ក្នុងចំណោមមូលហេតុសំខាន់ៗមួយចំនួនទៀត ។ ចំណែកនៅភូមិណាយ ភូមិតាំងម្លូ (ឈ្មោះផ្លូវការ "ភូមិតាំង សេ") ភូមិកាណាតធំ (ឈ្មោះផ្លូវការ "ភូមិកាណាត") ភូមិតាណង បានចាត់ទុកថាទឹកជំនន់លិចស្រែចំការ ដែលកើតមានឡើងញឹកញាប់ជាមូលហេតុសំខាន់ជាងគេបំផុតទី ១ ដែលបណ្ដាលឱ្យអ្នកភូមិសំរេចចិត្តចាកចេញទៅរស់នៅឆ្ងាយពីទន្លេសេសាន ។

យោងតាមលទ្ធផលពិភាក្សាជាក្រុមរបស់ប្រជាជនចំនួន ៧ ភូមិ ខាងលើបង្ហាញអោយយើងឃើញយ៉ាងច្បាស់លាស់ថាមានភូមិចំនួន ៤ បានចាត់ទុកទឹកជំនន់ជាមូលហេតុសំខាន់ទីពីរសំរាប់ការចាកចេញរបស់អ្នកភូមិ ចំណែកឯ ៣ ភូមិ ទៀតបានចាត់ទុកវាជាមូលហេតុដ៏សំខាន់បំផុតទី១ ។ ខាងក្រោមនេះគឺជាសំដីរបស់អ្នកភូមិជនជាតិដើមភាគតិចដែលបានចាកចេញពីទីលំនៅចាស់តាមមាត់ទន្លេ ។

*លោក **សេរ៍ គីន** ជាជនជាតិដើមភាគតិចចារាយនៅភូមិតាំងជិកបាននិយាយថា "គ្រួសារខ្ញុំបានចំណាយពេល និងកំលាំងយ៉ាងច្រើនសំរាប់ដាំស្រូវ និងបន្លែប៉ុន្តែជាលទ្ធផលផលស្រូវ និងបន្លែដែលខ្ញុំសង្ឃឹមថានឹងទទួលបានបែរជាត្រូវទឹកជំនន់បំផ្លាញច្រើនដង ។ យើងមិនអាចស៊ូទ្រាំនឹងការបំផ្លាញរបស់ទឹកជំនន់បានទៀតទេ យើងត្រូវទៅរស់នៅកន្លែងថ្មីដែលទឹកជំនន់មិនអាចលិចស្រែចំការយើងបាន ។"*

*លោក **សេង ផ្ទាន** ជាអ្នកភូមិជនជាតិចារាយនៅភូមិ ដាលប៉ក់ បានប្រាប់ពីការសំរេចចិត្តរបស់គាត់ថា "ខ្ញុំស៊ូទ្រាំរស់នៅតាមដងទន្លេយូរណាស់មកហើយ ហើយទឹកជំនន់បានបំផ្លាញស្រូវក្នុងស្រែ និងបន្លែចំការខ្ញុំច្រើនដងដែរ ។ ខ្ញុំមិនអាចទុកអោយ ទឹកជំនន់បំផ្លាញស្រូវ និងបន្លែខ្ញុំទៀតទេ អញ្ចឹងហើយទើបខ្ញុំសំរេចចិត្តមករស់នៅឆ្ងាយពីទន្លេ ។"*


លំនៅដ្ឋានដែលត្រូវបំផ្លាញដោយទឹកជំនន់

ជនជាតិដើមភាគតិចព្រៅទាំង ២២ គ្រួសារ នៅភូមិកិគួងក្រោម ឃុំតាវែងក្រោម ស្រុកតាវែងបានសំរេចរើ ភូមិរបស់ខ្លួនទៅពីតំបន់ទំនាបទៅកាន់តំបន់ខ្ពស់ៗ បន្តិច និងនៅឆ្ងាយពីទន្លេជាងមុន ដោយមូលហេតុចំបងគឺទឹកជំនន់ លិចភូមិញឹកញាប់ ។ អ្នកភូមិបានប្រាប់អោយដឹងថា ទីតាំងភូមិចាស់ត្រូវទឹកលិចស្ទើរតែរាល់ឆ្នាំ ជាពិសេសនៅរដូវវស្សា ហើយជួនកាលក្នុងមួយឆ្នាំលិចរហូតដល់ ៣-៤ ដង ក៏មាន ដែលនេះដោយសាររបបទឹកមិនទៀងទាត់ដូចមុន ។ ម្យ៉ាងទៀតអ្នកភូមិនៅចងចាំមិនភ្លេចនូវការរងគ្រោះដ៏ធ្ងន់ធ្ងរបំផុតដោយសារទឹកជំនន់នៅឆ្នាំ ១៩៩៦ ។ នៅពេលនោះ ប្រជាជនក្នុងភូមិចំនួន ៥០ នាក់ ក្នុងនោះមានក្មេង ១២ នាក់ ត្រូវបានស្លាប់ដោយសារជំងឺអាសន្នរោគដែលកើតមកពី ទឹកក្រោយពេលទឹកជំនន់ ឆ្នាំ ១៩៩៦ និងទឹកជំនន់ក្រោយៗមកទៀត ។

*លោក **ពួស ពិន** អ្នកភូមិកិគួងក្រោម បានប្រាប់អោយដឹងថា អ្នកភូមិយើងរើភូមិថ្មីចេញពីមាត់ទន្លេសេសាន ពីព្រោះយើងមិនចង់ធ្វើចំការតាមដងទន្លេសេសានដែលត្រូវទឹកលិចរាល់ឆ្នាំ និងដោយសារមានអ្នកភូមិឈឺស្លាប់ច្រើន និងសត្វចិញ្ចឹមក៏ងាប់ច្រើនដែរ ។*

អ្នកភូមិជនជាតិដើមភាគតិចទំពួន និងជនជាតិឡាវដែលបានចាកចេញពីភូមិចាស់ទៅរស់នៅភូមិថ្មីនៅស្រុក វ៉ឺនសៃ បានជំរាបអំពីការសំរេចចិត្តចាកចេញពីទន្លេសេសានថា ប្រជាជនយើងរងគ្រោះខ្លាំងណាស់ដោយសារទឹកជំនន់លិចបំផ្លាញ ស្រែចំការ និងព្រទ្យសម្បត្តិជាច្រើន ។ អ្នកភូមិលើកឡើងអំពីការឈឺចាប់នេះថា ទឹកជំនន់នៅអំឡុងឆ្នាំ ១៩៩៦-២០០០ បានញាំញីជីវភាពរស់នៅរបស់ប្រជាជនយើង យ៉ាងធ្ងន់ធ្ងរ ពីព្រោះស្រែចំការដែលយើងបានចំណាយពេល និង កំលាំងយ៉ាងច្រើនធ្វើត្រូវបាន ទឹកជំនន់បំផ្លាញឥតឈប់ឈរ ។ បើវានៅតែបែបនេះទៅមុខទៀត តើឱ្យអ្នកភូមិយើងរស់នៅដោយរបៀបណា? ក្រុមសិក្សាបានរកឃើញថា មូលហេតុបោះបង់ទីលំនៅដែលសំខាន់បំផុតរបស់អ្នកភូមិ គឺដោយសារទឹកជំនន់លិច បំផ្លាញស្រែចំការ ។

*លោក **សៀង ពើហុប** ជនជាតិគ្រឹងរស់នៅតំបន់ថ្មី អូរផ្អាំង (ចេញពីភូមិ ផាក់ណាម) បានប្រាប់អោយដឹងថា "ពេលទឹកជំនន់លិចភូមិ ស្រែចំការខ្ញុំក៏លិច គោ ក្របី និងមាន់ងាប់ចំណែកវត្ថុបុរាណប្រពៃណីផ្សេងៗ ត្រូវបាត់បង់ហើយខ្ញុំ ត្រូវជួលទូកគេសំរាប់ធ្វើដំណើរទៀតផង ។ មិនតែប៉ុណ្ណោះ ស្រូវនៅក្នុងជង្រុកក៏ត្រូវស្អុយរលួយអស់ពេលនោះ ខ្ញុំបាន លក់ក្របីគោ និងមាសខ្លះដែលសល់ដើម្បីដោះ ស្រាយជីវភាពគ្រួសារ ។"*


ស្រូវរបស់អ្នកភូមិនៅតាមដងទន្លេសេសានដែលត្រូវបំផ្លាញបានដោយទឹកជំនន់

### ៥.២.២ ខ្លាចទំនប់បាក់

លោក **សេរ ស្វែន** ប្រធានក្រុមប្រឹក្សាឃុំសេសាន ស្រុកអូរយ៉ាដាវ បានមានប្រសាសន៍ថា គ្រួសារជាច្រើន នៅភូមិផាដល បានចាប់ផ្តើមជំលៀសកូនចៅទៅរស់នៅតាមចំការ ចំណែកឯចាស់ៗវិញអាចចេញចូលភូមិតាមធម្មតា ពេលមានការងារត្រូវធ្វើហើយបើទំនប់បាក់មែន ទោះបីជាយើងចាស់ៗ ស្លាប់ក៏នៅមានក្មេងៗ ជំនាន់ក្រោយរស់ដែរ ។ គាត់បានបន្ថែមទៀតថា ដោយសារតែភ័យខ្លាច ទំនប់បាក់នៅ ៣-៤ ឆ្នាំ ទៀត នឹងមានប្រជាជនយ៉ាងច្រើនចាកចេញពី ភូមិ ពីព្រោះអ្នកភូមិបានចាប់ផ្តើមរៀបចំផ្ទះសំរាប់រស់នៅតាមចំការនៅតំបន់ខ្ពស់ៗ និងតំបន់ភ្នំរួចខ្លះហើយ ។

*លោក **រម៉ាម ម្វិ** អ្នកភូមិផាដាល បានប្រាប់អោយដឹងថា "ឥឡូវនេះយ៉ាងហោចណាស់ក៏មានប្រជាជនចំនួន ១៨ គ្រួសារ ដែលបានរៀបចំចំការ សំភារៈប្រើប្រាស់ និងសង់ផ្ទះនៅតំបន់ភ្នំសំរាប់ជំលៀសកូនចៅ និងទៅរស់នៅ ទីនោះ ។"*

*អ្នកស្រី **រម៉ាស វិន** ជនជាតិចារាយរស់នៅភូមិភិ បាននិយាយថា "រាល់ថ្ងៃនេះខ្ញុំរស់នៅដោយភ័យខ្លាចទឹកឡើងខ្លាំង និងទំនប់បាក់ខ្លាំងណាស់ មិនថាពេលថ្ងៃ ឬពេលយប់ឡើយ ។" គាត់បន្តថា "ខ្ញុំដេកមិនសូវលក់ទេ ពេលយប់ ហើយជារឿយៗ ខ្ញុំដើរទៅមើលទឹកទន្លេទាំងកណ្តាលយប់ខ្លាចវា ឡើងខ្លាំង ។"*


ទំនប់យ៉ាលីដែលសាងសង់នៅផ្នែកខាងលើនៃទន្លេសេសានក្នុងប្រទេសវៀតណាម

ក្នុងចំណោមភូមិចំនួន ៧ ដែលបាន សិក្សា នៅស្រុកអណ្តូងមាស អ្នកបោះបង់ទីលំនៅចេញពី ទន្លេមាន ៤ ភូមិ គឺភូមិកាជូត ភូមិញ៉ាង ភូមិតាំងជិក និងភូមិដាលប៉ក់ (ឈ្មោះផ្លូវការ "ភូមិដាល") បាន កំណត់ថា ភាពភ័យខ្លាចទំនប់បាក់ គឺជាមូលហេតុដ៏ សំខាន់បំផុត ដែលជំរុញអោយអ្នកភូមិសំរេចចិត្តមក រស់នៅតាមតំបន់ភ្នំឆ្ងាយពីទន្លេ។ អ្នកភូមិបានកំណត់ មូលហេតុនៃការបោះបង់ទីលំនៅ ២ ផ្សេងទៀតផងដែរ គឺទឹកជំនន់លិចញឹកញាប់ និងខ្វះខាតស្បៀងអាហារ ។

អ្នកភូមិ ៥ នាក់ ក្នុងចំណោម ១៣ នាក់ ដែលក្រុមសិក្សាបានសម្ភាសនៅក្នុងភូមិទាំង ៧ បាននិយាយថា អ្នកភូមិសំរេចចិត្តមករស់នៅឆ្ងាយពីទន្លេដោយមូលហេតុសំខាន់បំផុតគឺខ្លាចទំនប់បាក់។ ចំណែកអ្នកភូមិ ០៦ នាក់ ទៀត ឆ្លើយថា អ្នកភូមិសំរេចចិត្តចាកចេញពីទន្លេ ដោយសារទឹកជំនន់ញឹកញាប់ និង ០២ នាក់ ផ្សេងទៀត នៅភូមិតាណង ប្រាប់ថាមកពីខ្វះដីសំរាប់ពង្រីកភូមិ និងស្រែចំការ ។

ប្រជាជនដែលបោះបង់ទីលំនៅបានបង្ហាញការយល់ឃើញថាទោះបីជាទំនប់យ៉ាលីមិនទាន់បាក់នៅថ្ងៃនេះ ប៉ុន្តែវានឹងកើតឡើងនៅពេលមិនយូរខាងមុខនេះ ពីព្រោះទំនប់នេះមានអាយុជាង ១០ឆ្នាំ ហើយ។ អ្នកភូមិបានបន្ថែម ទៀតថា គេសាងសង់ទំនប់ពីស៊ីម៉ង់ និងដែកប៉ុណ្ណោះ ដូចនេះវាមិនអាចនៅជាប់បានរហូតទេ។ ប្រសិនបើយើងទ្រាំ រស់នៅតាមដងទន្លេទៀត គឺមានន័យថាយើងនៅរងចាំទឹកជំនន់ (ដោយសារការបាក់ទំនប់យ៉ាលី) សំលាប់យើង ហើយ ។

*អ្នកស្រី រម៉ាស ផ្សុត អាយុ ៤៥ ឆ្នាំ ជាជនជាតិចារាយ ដែលរស់នៅភូមិដាលប៉ក់បានបង្ហាញអំពីការសំរេចចិត្តមករស់នៅឆ្ងាយពីទន្លេថា "ខ្ញុំជាស្ត្រីពិតជាខ្លាចទំនប់បាក់ខ្លាំងណាស់ ពីព្រោះបើសិនជាទំនប់បាក់ខ្ញុំមិនអាចរត់គេច ចេញពីទឹកទន្លេរួចទេ ហើយបើចង់ឡើងដើមឈើក៏មិនអាចឡើងរួចដែរ។ អញ្ចឹងដើម្បីរស់ដោយសេចក្តីសុខ អស់ក្តី ភ័យខ្លាចគ្រប់ពេលវេលា ខ្ញុំត្រូវតែសំរេចចិត្តមករស់នៅលើភ្នំទើបទឹកទន្លេមិនអាចលិចដល់ ។"*

*អ្នកស្រី រចំ បឿយ អាយុ ៤៥ ឆ្នាំ ជាជនជាតិចារាយ ដែលសព្វថ្ងៃកំពុងរស់នៅក្នុងភូមិញ៉ាងបាននិយាយថា "ចាប់តាំងពីឆ្នាំ ១៩៩៩ មក ស្រូវ និងបន្លែក្នុងចំការមិនដែលទឹកលិចឡើយ។ ហើយពេលរស់នៅទីនេះ ខ្ញុំមិនឈឺច្រើន គឺមានជំងឺបន្តិចបន្តួចតាមធម្មតា ជាពិសេសខ្ញុំអាចដេកលក់បានយ៉ាងស្រួលដោយមិនព្រួយបារម្ភពីទឹកលិច និងទំនប់បាក់ ឡើយ ។"*

*លោក រចំ សឿន ប្រធានភូមិញ៉ាង បង្ហាញអារម្មណ៍ភ័យខ្លាចរបស់ប្រជាជនពេលជួបប្រទះទឹកជំនន់ខ្លាំងនៅ ឆ្នាំ ១៩៩៦ ថា "ប្រជាជនគ្រប់រូបនៅភូមិញ៉ាងភ័យញ័រជង្គង់ ញ័រខ្លួនយ៉ាងខ្លាំងពេលទឹកកំពុងលិចភូមិ ។ ផ្ទះ សំភារៈ ផ្សេងៗ គោ ក្របី មាន់ត្រូវទឹកទន្លេកួចនាំយកទៅច្រើនណាស់។ ពេលនោះនៅក្នុងភូមិមានទឹកបាញ់ឡើងចេញពីផ្ទៃ ទឹកយ៉ាងខ្ពស់ ប្រជាជនរឹតតែភ័យខ្លាចខ្លាំងឡើងៗ ពេលឃើញទឹកបាញ់នោះ។ យើងពិតជាមិនចង់ជួបប្រទះនឹងរឿង នេះទៀតទេ ដូចនេះទើបអ្នកភូមិ ចាស់ទុំ និងប្រធានភូមិបានប្រជុំគ្នាសំរេចមករស់នៅលើភ្នំ ពីព្រោះយើងយល់ឃើញ ថាកាលណាមានទឹកជំនន់លិច វាមានគ្រោះថ្នាក់ខ្លាំងណាស់ ជាពិសេសសំរាប់ក្មេងៗ ស្ត្រី ចាស់ទុំ និងជនពិការ ។"*

ប្រហាក់ប្រហែលគ្នានេះដែរ ជនជាតិដើមភាគតិចមួយចំនួននៅស្រុកវឺនសៃដែលបានបោះបង់ទីលំនៅទៅតំបន់ ភ្នំឆ្ងាយពីទន្លេសេសាន បានអះអាងថា ការសំរេចចិត្តចាកចេញពីទន្លេសេសាននេះក៏មានការទាក់ទងនឹងសេចក្តីភ័យខ្លាចនៃការបាក់ទំនប់ និងទឹកឡើងខ្លាំងមិនទៀតទាត់ដែរ ។

*លោក **លុច កាឡៅ** ជនជាតិព្រៅ ជាអ្នកភូមិប៉ាតឹង ឃុំកោះប៉ង់ ដែលបានចាកចេញពីទន្លេសេសានទៅរស់នៅតំបន់ភ្នំបានប្រាប់អោយដឹងថា "ពីព្រោះខ្ញុំធ្លាប់ឆ្លងកាត់សម័យសង្គ្រាមច្រើនដងក៏ខ្ញុំមិនស្លាប់ផង ដូចនេះខ្ញុំមិនទ្រាំរង់ចាំអោយខ្លួនខ្ញុំស្លាប់ដោយសារទំនប់បាក់ទេ ។"*

ឆ្លងតាមការបកស្រាយខាងលើយើងឃើញថា ទឹកជំនន់ដែលកើតឡើងញឹកញាប់ ជាពិសេសទឹកជំនន់នៅក្នុង ឆ្នាំ ១៩៩៦ របបទឹកឡើងចុះមិនទៀងទាត់ ពេលខ្លះស្រកពេលខ្លះឡើង ពេលខ្លះចរន្តទឹកអាចឡើងខ្លាំងភ្លាមៗ ដែលបានបង្ហាញអោយអ្នកភូមិឃើញផ្ទាល់នឹងភ្នែក ជាសញ្ញាគ្រោះថ្នាក់សំរាប់អ្នកភូមិគ្រប់ពេលវេលា ។ ម្យ៉ាងទៀត ទឹកជំនន់ទន្លេសេសានបានធ្វើអោយមនុស្ស ៣២ នាក់ស្លាប់ និងទ្រព្យសម្បត្តិយ៉ាងច្រើនទៀតត្រូវបានបំផ្លាញ ។

ទឹកជំនន់ទាំងនេះគឺជាស្នាដៃដ៏អាក្រក់របស់ទំនប់យ៉ាលីដែលប្រជាជនដែលកំពុងរស់នៅតាមដងទន្លេ និងអ្នក ដែលបានចាកចេញទៅរស់នៅឆ្ងាយពីទន្លេដឹងយ៉ាងច្បាស់ ។ ផលប៉ះពាល់ដែលទំនប់យ៉ាលីបាន និងកំពុងផ្តល់ទាំងអស់នេះ បានធ្វើអោយប្រជាជនដែលកំពុងរស់នៅតាមដងទន្លេសេសាន ជាពិសេសអ្នកដែលបានចាកចេញពីទន្លេមានអារម្មណ៍ភ័យខ្លាចទាំងយប់ទាំងថ្ងៃ ហើយវាជាការពិតអារម្មណ៍ភ័យខ្លាចនេះបានបង្ខំអោយអ្នកភូមិទៅរស់នៅឆ្ងាយពីទន្លេ ។

### ៥.២.៣ បញ្ហាសន្តិសុខស្បៀង

#### ក. ទឹកជំនន់លិចបំផ្លាញស្រូវញឹកញាប់

ទឹកជំនន់បានបង្កអោយមានបញ្ហាយ៉ាងធំ ដែលពាក់ពន្ធ័នឹងសន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋដែលរស់នៅតាម ដងទន្លេសេសាន ។ នៅកំឡុងឆ្នាំ ១៩៩៦ ដល់ ២០០១ ទឹកជំនន់បានកើតមានឡើងយ៉ាងញឹកញាប់ ហើយផលស្រូវ ចំការ បន្លែ ដំណាំ និងទ្រព្យសម្បត្តិរបស់អ្នកភូមិជាច្រើនត្រូវបានបាត់បង់ និងខូចខាតយ៉ាងធ្ងន់ធ្ងរ ។ ជាការពិតណាស់ ជីវភាពរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនដែលពឹងផ្អែកលើធនធានធម្មជាតិ និងធនធានដទៃទៀត នៅក្នុងទន្លេ ហើយប្រជាជនទាំងនេះមិនមានជំរើសណាផ្សេងក្រៅពីសង្ឃឹមលើផលស្រូវ ចំការ និងដំណាំរួមផ្សំផ្សេងៗ ឡើយ ។

ជាការពិតទឹកជំនន់លិចបំផ្លាញស្រូវស្រែ ចំការ និងដំណាំរួមផ្សំមួយឆ្នាំធ្វើឱ្យអ្នកភូមិប្រើរយៈពេលពី ២ ទៅ ៣ ឆ្នាំ ដើម្បីស្តារនូវស្ថានភាពស្បៀងអោយបានប្រសើរឡើងវិញ ។ មានអ្នកភូមិជាច្រើនបានពង្រីកចំការ និងកាប់ចំការ ថ្មីនៅតំបន់ខ្ពស់ៗ ឆ្ងាយពីទន្លេ ដែលទឹកជំនន់មិនអាចលិចដល់ ចាប់តាំងពីពួកគេបានទទួលរងគ្រោះពីទឹកជំនន់កន្លងមក ។ ហើយជាទូទៅ ក្រោយពេលអ្នកភូមិមានចំការគ្រប់គ្រាន់នៅតំបន់ភ្នំរួចហើយ ទើបពួកគេផ្លាស់ទៅរស់ទីនោះ ដោយពឹងអាស្រ័យលើធនធានព្រៃឈើ ដីភ្នំ និងទឹកច្រប់អូរសំរាប់ការចិញ្ចឹមជីវិតវិញ។ ក្រុមសិក្សា

បានរកឃើញថា មានប្រជាជន ១៥ គ្រួសារ នៅភូមិប៉ាដល , ២០ គ្រួសារ នៅភូមិកាតាង និង ២៥ គ្រួសារ ទៀតនៅភូមិភិ ក្នុងឃុំ សេសាន ស្រុកអូរយ៉ាដាវ បាននិង កំពុងកាប់ចំការថ្មី និងរៀបចំកន្លែងថ្មីសំរាប់រស់នៅ (តាមតំបន់ភ្នំ) ។ អ្នកភូមិទាំង នេះ កន្លងមកធ្លាប់រស់នៅ និងពឹងអាស្រ័យលើទន្លេសេសានយូរមកហើយ ប៉ុន្តែពេលនេះពួកគេបែរជាមានបំណងចាក ចេញពីទន្លេទៅវិញ ។ ដូចនេះសំរាប់ស្រុកអូរយ៉ាដាវ យ៉ាងហោចណាស់ក៏មានប្រជាជនប្រមាណ ៦០ គ្រួសារ កំពុង ត្រៀមរៀបចំខ្លួនចាកចេញពីទន្លេសេសាន ដោយសារមូលហេតុទឹកជំនន់ញឹក ញាប់ និងសេចក្តីភ័យខ្លាចទំនប់បាក់ ។

## ខ. ការបាត់បង់ធនធានទន្លេ


ផលត្រីដែលនេសាទបានធ្លាក់ចុះយ៉ាងខ្លាំង និងគួរអោយព្រួយបារម្ភ

អ្នកភូមិតាមដងទន្លេសេសានបានត្អូញត្អែរថា ពីមុនអ្នកភូមិរស់នៅដោយពឹងអាស្រ័យ លើធនធានទន្លេសំខាន់បំផុតដែលធនធានទាំងនោះរួមមានត្រី ទឹក បន្លែព្រៃ និងរ៉ែមាសតាមដងទន្លេ ជាដើម ប៉ុន្តែអ្នកភូមិបាននិយាយថាធនធានទន្លេចាប់ផ្តើមធ្លាក់ចុះ និងបាត់បង់រហូតចាប់តាំងពីឆ្នាំ ១៩៩៦ មក ។ ទាក់ទងនឹងចំណុចនេះអ្នកភូមិកត់ចំណាំថាត្រីបានចាប់ផ្តើមធ្លាក់ចុះយ៉ាងខ្លាំង ចាប់តាំងពីទំនប់នេះបង្កផលប៉ះពាល់មកលើទន្លេសេសាន ហើយមកដល់សព្វថ្ងៃនេះអ្នកភូមិរកត្រី បានតិចតួចបំផុតសំរាប់ហូប ហើយពេលខ្លះរកមិនបានសោះក៏មានដែរ ។ អ្នកភូមិខ្លះដែលធ្លាប់រកត្រី សំរាប់ហូបជាប្រចាំបានបោះបង់មុខរបររក ត្រីដោយសារតែការធ្លាក់ចុះនៃផលត្រីនេះ ។ ត្រី និងបន្លែ តាមដងទន្លេជាប្រភពស្បៀងដ៏សំខាន់សំរាប់ប្រជាជនរស់នៅតាមដងទន្លេសេសាន ដូចនេះ បើធនធានទាំងនេះត្រូវបានបាត់បង់នោះស្បៀងអាហារអ្នកភូមិពិតជាជួបប្រទះបញ្ហាមិនខាន ។

*លោក រម៉ាម មែល ប្រធានភូមិដាលប៉ក់ ឃុំញ៉ាង ស្រុកអណ្តូងមាស បានរៀបរាប់ថា "បើនិយាយអំពីទន្លេ សេសានវិញ ប្រជាជនយើងលែងមានក្តីសង្ឃឹមថាអាចពឹងអាស្រ័យលើទន្លេសេសានទៀតហើយ ពីព្រោះធនធានទន្លេ ានបាត់បង់ស្ទើរអស់រលីងទៅហើយ ។"*

## គ. បាត់បង់ប្រភពរកប្រាក់ចំណូលតាមគ្រួសារ


ការបាក់ច្រាំងទន្លេបានបំផ្លាញសួនដំណាំនៅតាមច្រាំងទន្លេ

ចាប់តាំងពីឆ្នាំ ១៩៩៦ មកប្រជាជនរស់នៅតាមដងទន្លេសេសានបានបាត់បង់ប្រភពរក ប្រាក់ចំណូលសំខាន់ៗ មួយចំនួនដែលពួកគេធ្លាប់តែរកបានដូចជាការរែងមាស លក់ត្រីដែលនេសាទ បាន និងលក់បន្លែដែលដាំតាមដងទន្លេ ។ ប្រភពប្រាក់ចំណូលទាំងនេះមានសារៈសំខាន់ណាស់សំរាប់ ដោះស្រាយបញ្ហា ស្បៀងអាហារក្នុងគ្រួសារ ។ ហើយដោយសារតែអ្នកភូមិគ្មានប្រាក់ចណ្ណូលសំរាប់ ដោះស្រាយ ទើបពេលខ្លះស្បៀងម្តងៗពួក គេត្រូវប្រឈមមុខនឹងគ្រោះអត់ឃ្លាន ត្រូវខ្ចីបុលពីអ្នក ភូមិជិតខាង លក់សត្វ ចិញ្ចឹម ឬចេញទៅរកការងារធ្វើជាកម្មករ អោយគេសំរាប់រកប្រាក់ទិញ អង្ករ ។ អ្នកភូមិមិនមែនជាអ្នកពូកែខាងរកប្រាក់ចំណូលសំរាប់ចិញ្ចឹមគ្រួសារទេ គឺ គ្រួសារអ្នក

ភូមិអាចរស់បានដោយអាស្រ័យលើផលស្រែចំការ និងធនធាន ធម្មជាតិផ្សេងៗ ដែលទទួលបានរៀងរាល់ឆ្នាំ ។ ដូចនេះការដែលប្រឈមមុខនឹងការរកប្រាក់ចំណូលសំរាប់ដោះស្រាយការខ្វះខាតស្បៀងអាហារ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរសំរាប់ប្រជាជននៅតាមដងទន្លេ ជាពិសេសជនជាតិដើមភាគតិច ។

### ៥.២.៤ ចង់បានចំការថ្មី និងការពារដីកុំអោយអ្នកខាងក្រៅភូមិចាប់យក

ក្រុមសិក្សាបានរកឃើញថា អ្នកចាកចេញពីទន្លេមួយចំនួននៅស្រុកអណ្តូងមាស និងស្រុកវីនសៃបានសំរេចចិត្តចាកចេញដោយមានបំណងចង់បានចំការថ្មី និងការពារដីកុំអោយអ្នកខាងក្រៅភូមិចាប់យក ។

គួរអោយកត់សំគាល់ថាប្រជាជនមួយចំនួននៅភូមិតាំងម្លូ (ឈ្មោះផ្លូវការ "ភូមិតាំងសេ") បានអះអាងថា ហេតុផលមួយផ្នែកដែលជំរុញអោយផ្លាស់ទីលំនៅទីនេះ គឺដោយសារតែអ្នកភូមិចង់ការពារដីពីការរំលោភបំពានពីអ្នកខាងក្រៅ ជាក់ស្តែងក្រុមហ៊ុនឯកជន ។ អ្នកភូមិបញ្ជាក់ទៀតថា ប្រសិនបើយើងមិនថែរក្សាដីសំរាប់ធ្វើចំការ និងពង្រីកចំការនៅពេលនេះទេ នោះកូនចៅជំនាន់ក្រោយពិតជាគ្មានដីសំរាប់ធ្វើចំការឡើយ ។

*អ្នកស្រី **ភិន សូនី** អាយុ ៤៤ ឆ្នាំ ជនជាតិទំពួន ដែលមានសមាជិកគ្រួសារចំនួន ៨ នាក់ បានចាកចេញឆ្ងាយ ពីភូមិកាចូនក្រោម ស្រុកវីនសៃដែលស្ថិតនៅតាមដងទន្លេសេសាន មករស់នៅតំបន់ភ្នំតាំងពីឆ្នាំ ២០០១ ។ គាត់បាន ប្រាប់អោយដឹងថា "គ្រួសារខ្ញុំសំរេចចិត្តមករស់នៅទីនេះដោយសារយើងចង់បានចំការថ្មីសំរាប់ដាំចន្ទី ។"*

*លោក **ហា ស៊ីណាន** ជនជនជាតិទំពួន និងជាប្រធានឃុំកាចូនបាននិយាយថា "វាជាការល្អប្រសើរហើយដែល ប្រជាជនខ្លះក្នុងភូមិមករស់នៅតំបន់ថ្មីនេះ ពីព្រោះប្រជាជននៅក្នុងភូមិតែងតែកើនឡើងជានិច្ច ប្រសិនបើអ្នកភូមិមិន មករស់នៅទីនេះឱ្យទាន់ពេលវេលាទេ ដីនៅតំបន់នោះនឹងត្រូវបានអ្នកខាងក្រៅមកប្រើប្រាស់មុនជាមិនខានឡើយ ។"*

## ៥.៣ ឥទ្ធិពលនៃការចាកចេញពីទន្លេសេសាន

### ៥.៣.១ ឥទ្ធិពលវិជ្ជមាននៃការផ្លាស់ទីលំនៅ

#### ក. សន្តិសុខស្បៀង

ជាទូទៅអ្នកភូមិដែលមករស់នៅតំបន់ថ្មីបានរស់នៅក្នុងជីវភាពមួយសមរម្យជាងកាលដែលពួកគេរស់នៅតាមដងទន្លេសេសាន ។ ដោយសារតែនៅតំបន់ថ្មីនោះពុំមានទឹកជំនន់ទៅដល់ វិងស្រូវស្រែចំការក៏ទទួលបានផលល្អ ការរកប្រាក់ចំណូល និងសត្វចិញ្ចឹមក៏បានល្អប្រសើរ ។ យើងសង្កេតឃើញថាប្រជាជនដែលទើបទៅរស់នៅតំបន់ថ្មីក្នុងរយៈ ពេល ១-២ ឆ្នាំ មានការជួបប្រទះនឹងការខ្វះខាតស្បៀងអាហារ ដោយសារអ្នកភូមិត្រូវការចំណាយពេលច្រើនលើការរៀបចំលំនៅដ្ឋានថ្មី និងកាប់ចំការថ្មី ។ នៅអំឡុងពេលបោះបង់ និងផ្លាស់ទីលំនៅដំបូង អ្នកភូមិមិនអាចទទួលបានផល ស្រូវចំការគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ជីវភាពឡើយ ។ ប៉ុន្តែក្រោយពេលរស់នៅតំបន់ថ្មីនោះរយៈពេល ៣ ឆ្នាំឡើងទៅ ផលស្រូវពីចំការអាចជួយផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារបានគ្រប់គ្រាន់ ។

*លោក **សៀង ពើហុប** ជនជាតិគ្រឹង នៅភូមិថ្មីអូរផ្លាំង ស្រុកវើនសៃ បានប្រាប់ថា "ការរស់នៅទីនេះខ្ញុំអាចទទួលបានផលស្រូវល្អ អាចហូបគ្រប់គាន់សំរាប់សមាជិកគ្រួសារ ១៤ នាក់ ។ ហើយយើងអាចរកត្រីនៅតាមអូរ រកបន្លែ និងសត្វក្នុងព្រៃសំរាប់ហូបបានស្រួល ។"*

ទីតាំងភូមិសាស្ត្រនៅតំបន់ភ្នំអាចផ្តល់លទ្ធភាពអោយអ្នកភូមិអាចដាំស្រូវ និងបន្លែចំរុះនៅក្នុងចំការបស់អ្នកភូមិបាន ។ ដូច្នេះអ្នកភូមិអាចទទួលបានផលស្រូវផង និងមានបន្លែសំរាប់ហូបប្រចាំថ្ងៃទៀត ។ ការរស់នៅស្ថិតក្នុងបរិយាកាសបែបនេះបានធ្វើឱ្យស្ថានភាពស្បៀងអាហាររបស់អ្នកភូមិកាន់តែប្រសើរបន្តិចម្តងៗ ។ ចំណែកឯប្រជាជនចំនួន ២០ គ្រួសារ មកពីភូមិបានប៉ុង និងភូមិចាចូនក្រោមនៅស្រុកវើនសៃដែលកំពុងរស់នៅតំបន់ព្រៃភ្នំវិញក៏មានស្ថានភាពស្បៀងល្អប្រសើរជាងកាលអ្នកភូមិរស់នៅតាមដងទន្លេដែរ ។ នេះអាចទាក់ទងនឹងធនធានព្រៃឈើដែលអាចប្រើប្រាស់បាន និងមានដីចំការគ្រប់គ្រាន់សំរាប់ដាំស្រូវ និងដំណាំផ្សេងៗ ទៀត ។

*អ្នកស្រី **ភិន សូនី** ជនជាតិទំពួននៅតំបន់អូរតាម៉ៅ ស្រុកវើនសៃ បាននិយាយថា "គ្រួសារខ្ញុំអាចដាំដុះបន្លែ សំរាប់ហូបក្នុងគ្រួសារ ដូចជាម្ទេស ត្រប់ និងត្រសក់ជាដើម ហើយយើងទទួលបានផលស្រូវចំការសំរាប់ហូបគ្រប់គ្រាន់ ។"*

*លោក **ពួស ពិន** ជនជាតិព្រៅ នៅភូមិកិគួងក្រោម បានប្រាប់អោយដឹងថា អ្នកភូមិទាំងអស់បានមករស់នៅ តំបន់ថ្មីនេះចាប់តាំងពីខែមករា ឆ្នាំ ២០០១ ។ ចាប់តាំងពីពេលនោះមកអ្នកភូមិនាំគ្នាធ្វើចំការតាមតំបន់ភ្នំ ហើយស្រូវ ចំការមិនដែលជន់លិចដោយសារទឹកទន្លេទៀតទេ ។ "គ្រួសារខ្ញុំទទួលបានផលស្រូវច្រើនជាងកាលនៅកន្លែងចាស់ ។"*

បន្តែគួរកត់សំគាល់ថា ការបោះបង់ និងផ្លាស់ទីលំនៅឃុំញ៉ាង ស្រុកអណ្តូងមាស ដែលកំពុងរស់នៅតំបន់ថ្មីដែលជាតំបន់ភ្នំដីក្រហមជួបប្រទះនឹងការខ្វះខាត់ស្បៀងយ៉ាងធ្ងន់ធ្ងរ ។ អ្នកភូមិដែលជួបប្រទះនេះមានទាំងអ្នកបានមករស់នៅយូរ និងអ្នកដែលទើបនឹងទៅរស់នៅថ្មីៗ ។ យោងទៅតាមអ្នកភូមិបានអោយដឹងថា ពួកគេជួបប្រទះនឹងការខ្វះខាតស្បៀងអាហារចាប់ពី ៥-១០ ខែ ឯណ្ណោះ ។

ការខ្វះខាតស្បៀងដ៏ធ្ងន់ធ្ងរនេះមិនមែនបណ្តាលមកពីគុណភាពដីចំការអ្នកភូមិទេ គឺបណ្តាលមកពី :

- ពុំមានសេសសល់ស្បៀងពីកន្លែងរស់នៅចាស់
- ពុំមានកំលាំងគ្រប់គ្រាន់សំរាប់ការកាប់ចំការថ្មី និង
- គ្រោះរាំងស្ងួតដែលកើតមាននៅរដូវវស្សាឆ្នាំ ២០០៥ ។

អ្នកភូមិបានប្រាប់អោយដឹងថា ប្រជាជនប្រមាណ ៩០% នៅក្នុងភូមិ កាជូត ភូមិណាយ ភូមិតាំងជិក ភូមិដាល ប៉ក់ (ភូមិថ្មី) ភូមិដាលព័រ (ភូមិថ្មី) ភូមិញ៉ាង ភូមិតាំងលោម (ភូមិថ្មី) ភូមិតាំងម្លូ (ភូមិថ្មី) និងភូមិញ៉ាង កំពុង ប្រឈមមុខ នឹងការខ្វះខាតស្បៀងនេះ ។ ប្រជាជនទាំងនេះភាគច្រើនគឺជាជនជាតិដើមភាគតិចចារាយ និងមានជនជាតិ កាចក់ និងទំពួនខ្លះដែរ ។ ទន្ទឹមនឹងនេះប្រជាជនដែលបានបោះបង់ទីលំនៅតាមស្រុកផ្សេងៗទៀត ក៏ជួបប្រទះនឹងការខ្វះខាតស្បៀងនេះផងដែរ ប៉ុន្តែវាស្ថិតនៅក្នុងកំរិតមួយធូរស្រាយជាងប្រជាជននៅឃុំញ៉ាង ។ ការខ្វះខាតស្បៀងនេះគឺ បណ្តាលមកពីគ្រោះរាំងស្ងួតនៅឆ្នាំ ២០០៥ តែប៉ុណ្ណោះ ។

## ខ. ការរកប្រាក់ចំណូល

ក្រុមសិក្សាបានរកឃើញថា អ្នកភូមិដែលបានបោះបង់ទីលំនៅចាស់ទៅរស់នៅតំបន់ថ្មី ដែលជាតំបន់ខ្ពស់ៗ ឬ តំបន់ភ្នំនោះ អាចមានឱកាសរកប្រាក់ចំណូលបានច្រើន និងមានលំនឹងជាងកាលអ្នកភូមិរស់នៅតាមដងទន្លេ ក្នុងកំឡុង ពេលក្រោយឆ្នាំ ១៩៩៦ ។ កត្តានេះមានការទាក់ទងយ៉ាងសំខាន់ទៅនឹងស្ថានភាពភូមិសាស្ត្រ និងធនធានធម្មជាតិនៅ តំបន់នោះ ។

អ្នកភូមិអាចរកប្រាក់ចំណូលបានខ្លះពីការលក់អនុផលព្រៃឈើផ្សេងៗ ដែលអាចរកបាននៅតាមតំបន់ព្រៃភ្នំ ដូចជា ផ្សិត ទំពាំង ឬស្សី និងប្រភេទសត្វព្រៃមួយចំនួន ។ ចំណូលពីការលក់អនុផលព្រៃឈើអាចចូលរួមចំណែកកែលំអរជីវភាពគ្រួសារពួកគាត់បានមួយកំរិតដែរ ។ម្យ៉ាងទៀតពួកគាត់ក៏អាចប្រមូលអនុផលព្រៃឈើសំរាប់ហូប ឬ លក់បានតិច ឬច្រើនដោយយោងទៅតាមស្ថានភាពភូមិសាស្ត្រនៃតំបន់ព្រៃដែលពួកគាត់ប្រើប្រាស់នៅទីនោះ ។

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសាររបស់អ្នកភូមិនៅតំបន់ថ្មី ក៏មានលក្ខណៈល្អប្រសើរជាងកាលអ្នកភូមិរស់នៅ តាមដងទន្លេសេសានផងដែរ ។ ជាទូទៅអ្នកភូមិទាំងនោះចិញ្ចឹមសត្វស្រុកមួយចំនួនដូចជា គោ ក្របី ជ្រូក និងមាន់ សំរាប់ផ្គត់ផ្គង់ម្ហូបអាហារក្នុងគ្រួសារ និងសំរាប់លក់ដូរខ្លះពេលត្រូវការប្រាក់សំរាប់ប្រើប្រាស់ ។ អ្នកភូមិទាំងនោះប្រាប់ថា ការចិញ្ចឹមសត្វនៅទីនេះបានផលល្អជាងកាលនៅតាមដងទន្លេសេសាន ពីព្រោះពុំសូវមានសត្វងាប់ច្រើន ។ ប្រសិនបើ សត្វចិញ្ចឹមនៅទីនេះ ឈឺក៏ឈឺជាលក្ខណៈធម្មតា និងមិនច្រើនដងដែរ ។

*លោក ក្លាន ល្វេន អាយុ ៣៣ ឆ្នាំ ជនជាតិចារាយនៅភូមិតាំងម្លូ ស្រុកអណ្តូងមាសបាននិយាយថា "គ្រួសារខ្ញុំអាចរកប្រាក់ចំណូលបានពី ៨០០,០០០-៩០០០,០០០រៀល (១៩៥-២១៩ ដុល្លា) ជាមធ្យមក្នុងមួយឆ្នាំ ពីការលក់ សត្វចិញ្ចឹមដូចជាគោ ក្របីជ្រូក ឬមាន់ ។"*

ម្យ៉ាងទៀតប្រជាជនដែលបានបោះបង់ទីលំនៅចេញពីទន្លេសេសានអាចរកប្រាក់ចំណូលបានច្រើនគួរសមពីការលក់គ្រាប់ស្វាយចន្ទី ។ ចំការដែលដាំស្វាយចន្ទី គេអាចដាំស្រូវ និងបន្លែផ្សេងៗ ទៀត នៅអំឡុង ៤ ឆ្នាំ ដំបូង ។

*លោក **ក្លាន បឿស** ជនជាតិចារាយនៅភូមិតាំងម្លូ ស្រុកអណ្តូងមាស បាននិយាយថា "គ្រួសារខ្ញុំអាចរក ប្រាក់ចំណូលបានពី ១០០,០០០- ១៥០,០០០រៀល ពីការលក់គ្រាប់ស្វាយចន្ទីក្នុងមួយឆ្នាំ ។"*

សំរាប់អ្នកភូមិបានប៉ុង និងភូមិកាចូនក្រោមវិញក៏បានដាំដំណាំស្វាយចន្ទីដែរ ហើយផលគ្រាប់ស្វាយចន្ទីដែល អ្នកភូមិប្រមូលបានរាល់ឆ្នាំ គឺជាការផ្តល់ប្រាក់ចំណូលយ៉ាងសំខាន់សំរាប់គ្រួសារ ។ អ្នកភូមិបាននិយាយថាគ្រាប់ស្វាយចន្ទីអាចលក់បានប្រហែល ៣០០,០០០រៀល ក្នុងមួយឆ្នាំ ( សំរាប់ដីចំការទំហំ ១ ហិចតា) ។

### គ. សុខភាព

ក្រុមសិក្សាបានរកឃើញថា អ្នកភូមិនៅតំបន់ថ្មីរស់នៅមានសុខភាពល្អគ្រាន់បើជាងកាលអ្នកភូមិរស់នៅតាមដងទន្លេ សេសាន ។ ពេលរស់នៅតំបន់ថ្មីនេះអ្នកភូមិមិនជួបប្រទះនឹងជំងឺច្រើនទេ ហើយប្រសិនបើមានជំងឺវិញ វាគ្រាន់តែជាជំងឺគ្រុន ធម្មតាតែប៉ុណ្ណោះ ។ ស្ថានភាពសុខភាពរបស់អ្នកភូមិអាចមាន ទំនាក់ទំនងទៅនឹងការប្រើប្រាស់ទឹកធនធានព្រៃ ឈើ និងម្ហូបអាហារប្រចាំថ្ងៃ ។


កុមារកើតរមាស់ដោយងូតទឹកទន្លេសេសាន

អ្នកភូមិបានប្រាប់ឱ្យដឹងថា ការរស់នៅទីនេះអ្នកភូមិ ប្រើប្រាស់ទឹកអូរ និងទឹកច្រប់ដែលមានប្រភពមកពីភ្នំ និងព្រៃឈើ ហើយទឹកធម្មជាតិនេះមិនបានធ្វើអោយអ្នកភូមិឈឺពោះ ឬកើតរមាស់ឡើយ ផ្ទុយទៅវិញវាអាចជួយទ្រទ្រង់សុខភាពអ្នកភូមិបានល្អ ។

### ឃ. មិនខ្លាចទំនប់បាក់

ការរស់នៅតំបន់ភ្នំ ឬតំបន់ខ្ពស់ឆ្ងាយពីទន្លេសេសានបានធ្វើអោយអារម្មណ៍របស់អ្នកភូមិទាំងនោះលែងភ័យ ខ្លាចទំនប់បាក់ ឬឈប់ខ្វល់ខ្វាយអំពីទឹកទំនន់លិចស្រែចំការទៀតហើយ ។ នៅពេលបាត់បង់អារម្មណ៍ភ័យខ្លាច និងការ ព្រួយបារម្ភទាំងនេះអស់ហើយ ទើបធ្វើអោយអ្នកភូមិដេកលក់បានស្រួលទាំងយប់ទាំងថ្ងៃ ។ អារម្មណ៍ល្អដែលអ្នកភូមិមានពេលរស់នៅតំបន់ថ្មីអាចជួយដល់ស្មារតីក្នុងការគិតគូអំពីការប្រកបរបរចិញ្ចឹមជីវិតបានល្អប្រសើរ ហើយវាក៏អាចជួយថែរក្សាសុខភាពអ្នកភូមិអោយបានល្អប្រសើរផងដែរ ។ ម្យ៉ាងទៀត អ្នកភូមិលែងព្រួយបារម្ភអំពីសុវត្ថិភាពកូនចៅរបស់គាត់ពេលគាត់មិននៅផ្ទះពីព្រោះនៅតំបន់ព្រៃភ្នំនេះទឹកទន្លេមិនអាចលិចដល់ឡើយទោះបីជាទំនប់បាក់ក៏ដោយ ។

*អ្នកស្រី **សៅ ញួន** ជនជាតិចារាយនៅភូមិដាលប៉ក់ ស្រុកអណ្តូងមាស បាននិយាយថា "ពេលរស់នៅតាម ដងទន្លេសេសាន ខ្ញុំភ័យខ្លាចទឹកទន្លេលិចភូមិទាំងយប់ទាំងថ្ងៃ ប៉ុន្តែឥឡូវគ្រួសារខ្ញុំមិនខ្លាចទឹកទន្លេលិចទៀតទេ ពីព្រោះ យើងបានមករស់នៅតំបន់ភ្នំខ្ពស់ហើយ ។"*

*អ្នកស្រី **សល ខុ** ជាជនជាតិចារាយដែលរស់នៅភូមិតាំងជិក ស្រុកអណ្តូងមាស បានប្រាប់អោយដឹងថា "ខ្ញុំមិនភ័យខ្លាចកូនខ្ញុំលង់ទឹកស្លាប់ក្នុងទន្លេទេពេលខ្ញុំមិននៅផ្ទះ ពីព្រោះទីនេះជាតំបន់ខ្ពស់ទឹកមិនអាច លិចដល់ទេ ។"*

## ៥.៣.២ ឥទ្ធិពលអវិជ្ជមាននៃការផ្លាស់ទីលំនៅ

### ក. បាត់បង់ដីស្រែចំការ



លំនៅដ្ឋានសង់ថ្មីនៅតំបន់ខ្ពស់ និងឆ្ងាយពីទន្លេ

ជាទូទៅក្រុមសិក្សាបានរកឃើញថា ក្នុងចំណោមអ្នកភូមិដែលបានចាកចេញពីទន្លេសេសាន មានអ្នកខ្លះបោះបង់ចោលដីលំនៅដ្ឋាន និងស្រែចំការដែលពួកគេធ្លាប់កាន់កាប់កាលរស់នៅតាមដងទន្លេ ចំណែកឯអ្នកភូមិខ្លះទៀតមិនបានបោះបង់ចោលស្រែចំការទាំងនោះទេ ។ សំរាប់អ្នកភូមិដែលមិនបោះបង់ចោលទ្រព្យសម្បត្តិទាំងនោះ ក្រុមសិក្សាបានរកឃើញថា អ្នកភូមិខ្លះរើផ្ទះចាស់របស់ខ្លួននៅតាមដងទន្លេទៅសង់នៅតំបន់រស់នៅថ្មីចំណែកដីស្រែចំការវិញ ត្រូវបានទុកចោលអោយនៅទំនេរមិនប្រើប្រាស់ ។

ជនជាតិដើមភាគតិចចារាយចំនួន ៤ គ្រួសារ នៅភូមិភិ ឃុំសេសាន ស្រុកអូរយ៉ាដាវ ដែលបានចាកចេញពីទន្លេ សេសានទៅរស់នៅតំបន់ភ្នំបានបោះបង់ដីស្រែចំការ ដីភូមិ ផ្ទះសំបែងនៅភូមិចាស់ចោលទាំងស្រុង ។ យោងតាមសំដី របស់លោកអនុប្រធានភូមិភិបានប្រាប់ឱ្យដឹងថា តាមការប៉ាន់ស្មានដីស្រែចំការសរុបដែលអ្នកភូមិបានបោះបង់មានទំហំ ប្រមាណ ១២ ហិចតា ។

តាមការប៉ាន់ស្មាន មានដីស្រែ និងចំការជាច្រើនដែលអ្នកភូមិចំនួន ១២ ភូមិ នៅក្នុងឃុំញ៉ាង ស្រុកអណ្តូង មាស បានបោះបង់ចោល ។ ប៉ុន្តែក្រុមសិក្សាមិនអាចរកអោយឃើញច្បាស់លាស់ថាមានទំហំប៉ុន្មានទេ ដោយយោងទៅ តាមផែនការសិក្សា និងពេលវេលាមានកំណត់ ។

ចំពោះអ្នកភូមិទាំង ២២ គ្រួសារ ដែលជាជនជាតិដើមភាគតិចព្រៅ នៅភូមិកិគួងក្រោម ឃុំតាវែងក្រោម ស្រុក តាវែងវិញមាន តែ ៦ គ្រួសារ ប៉ុណ្ណោះដែលធ្វើចំការតាមដងទន្លេសេសាន ។ ហើយក្រោយពេលអ្នកភូមិបានចាក ចេញពីទីតាំងភូមិចាស់មករស់នៅតំបន់ថ្មីក៏បានបាត់បង់ដីស្រែចំការមួយចំនួនផងដែរ ។ នេះដោយសារតែទឹកទន្លេលិច ចំការអ្នកភូមិញឹកញាប់ពេកទើបពួកគាត់សំរេចចិត្តបោះបង់ដីចំការទាំងនោះចោល ។

នៅស្រុកវ៉ឺនសៃ ក្រុមសិក្សាស្រាវជ្រាវបានរកឃើញមានភូមិចំនួន ៥ ក្នុងឃុំចំនួន ៤ ដែលបានបោះបង់ និង ផ្លាស់ប្តូរទីលំនៅពីភូមិចាស់ ភាគច្រើនជាជនជាតិដើមភាគតិច ចំណែកឯអ្នកភូមិមួយចំនួនទៀតគឺជាជនជាតិឡាវ ។ ក្នុង ចំណោមអ្នកភូមិទាំងនោះយើងសង្កេតឃើញថា មានអ្នកខ្លះបានទុកចោលមិនប្រើប្រាស់ដីស្រែចំការតាមដងទន្លេ ចំណែកឯអ្នកភូមិមួយចំនួនទៀតនៅតែបន្តការប្រើប្រាស់ដីស្រែចំការដែល ពួកគេធ្លាប់ធ្វើតាមដងទន្លេដដែល ។ អ្នកភូមិខ្លះចែកដីស្រែចំការទាំងនោះអោយសាច់ញាតិគ្រប់គ្រង និងប្រើប្រាស់ជំនួស ។ ជាទូទៅជនជាតិឡាវទាំងអស់ដែលបាន ចាកចេញពីទន្លេសេសានមិនបានបោះបង់ដីស្រែចំការរបស់ខ្លួនឡើយ ។ ជាក់ស្តែងជនជាតិឡាវចំនួន ២០ គ្រួសារ ដែលបានចាកចេញពីទន្លេសេសានពីភូមិបានប៉ុង ឃុំបានប៉ុង និងភូមិកាចូនក្រោម ឃុំកាចូន មិនបានបោះបង់ដីស្រែចំការដែល អ្នកភូមិធ្លាប់ធ្វើឡើយ ។ ពួកគេបានចែកដីស្រែចំការទាំងនោះអោយកូនសំរាប់គ្រប់គ្រង និងប្រើប្រាស់ ចំណែកឯអ្នកខ្លះ នៅតែកាន់កាប់ដីស្រែចំការដែលធ្លាប់ធ្វើពីមុនដដែល ។

## ខ. ការអប់រំ

ការអប់រំពិតជាមានសារៈសំខាន់ណាស់សំរាប់កុមារដែលគ្រប់អាយុចូលសិក្សា។ ប៉ុន្តែគួរឱ្យសោកស្តាយសំរាប់ កុមារទាំងឡាយដែលកំពុងរស់នៅជាមួយក្រុមគ្រួសារនៅតំបន់ថ្មីបានបាត់បង់ឱកាសទទួលការអប់រំសំរាប់អនាគតដ៏ភ្លឺស្វាងទៅហើយ ដោយសារតែតំបន់ដែលអ្នកភូមិកំពុងរស់នៅជាតំបន់ភ្នំហើយឆ្ងាយ ព្រមទាំងគ្មានផ្លូវសំរាប់ធ្វើដំណើរបានសមរម្យ។

សំរាប់ស្រុកអូរយ៉ាំងដាវ យ៉ាងហោចណាស់ក៏មានកុមារចំនួន ៥ នាក់ ក្នុងនោះមានកុមារី ៣ នាក់ ដែរ ដែលកំពុងរស់នៅតំបន់ភ្នំជាមួយគ្រួសារដោយមិនបានចូលរៀន។ កុមារា និងកុមារីទាំង ៥ នាក់ នោះគឺជាជនជាតិដើមភាគ តិចចារាយដែលធ្លាប់រស់នៅភូមិភិឃុំសេសាន។ បច្ចុប្បន្នកុមារដែលកំពុងរស់នៅក្នុងភូមិអាចចូលរៀននៅសាលាក្នុង ភូមិបាន ប៉ុន្តែចំពោះកុមារដែលចាកចេញពីភូមិតាមគ្រួសារមិនអាចចូលរៀនបានឡើយ។

ស្រុកអណ្តូងមាសជាស្រុកដែលមានប្រជាជនចាកចេញពីទន្លេសេសានច្រើនជាងគេ ទើបធ្វើអោយចំនួនកុមារ ដែលអត់បានទទួលការអប់រំមានចំនួនច្រើនជាងគេ ជាពិសេសគឺនៅឃុំញ៉ាង។ កុមារទាំងអស់នោះជាជនជាតិដើមភាគតិច ចារាយ កាចក់ ទំពួន ក្នុងនោះចារាយជាជនជាតិច្រើនជាងគេបំផុត បន្ទាប់មកកាចក់ និងទំពួន។ កុមារគ្រប់ អាយុចូលរៀនប្រមាណ ៦៥០ នាក់ ដែលកំពុងរស់នៅក្នុងភូមិតាំងជិក ភូមិដាលប៉ក់ ភូមិដាលព្ញ័រ ភូមិញ៉ាង ភូមិ តាំងលោម ភូមិតាំងម្លូ មិនបានចូលរៀនឡើយ។ ភូមិទាំងនេះគ្មានផ្លូវលំភូមិសំរាប់ធ្វើដំណើរបានសមរម្យឡើយ ហើយសេវាអប់រំរបស់សាលារដ្ឋ ក៏មិនមានដល់តំបន់ដែលអ្នកភូមិកំពុងរស់នៅដែរ។ គួរកត់សំគាល់ថា កុមារមួយចំនួនធ្លាប់ បានចូលរៀនថ្នាក់អប់រំក្រៅប្រព័ន្ធកាលរស់នៅតាមដងទន្លេ ប៉ុន្តែបច្ចុប្បន្នកុមារទាំងនោះមិនអាចរៀនបន្តទៀតឡើយ ក្រោយពេលទៅរស់នៅតំបន់ថ្មី។

*ជាក់ស្តែងកុមារនៅភូមិដាល់ប៉ក់បាននិយាយថា "កាលពួកយើងរស់នៅភូមិដាលតាមមាត់ទន្លេសេសាន យើង បានចូលរៀនថ្នាក់អប់រំក្រៅប្រព័ន្ធ។ យើងអាចសរសេរ និងអានអក្សរខ្មែរបានខ្លះដែរ ប៉ុន្តែពេលយើងផ្លាស់មករស់នៅ ទីនេះយើងអត់មានថ្នាក់អប់រំក្រៅប្រព័ន្ធរៀនបន្តទៀតទេ។"*

សំរាប់ភូមិណាយ និងកាដូតលើក៏មានកុមារមួយចំនួនធំមិនបានទទួលការអប់រំដោយសារការផ្លាស់ទីលំនៅថ្មីនេះដែរ ប៉ុន្តែក្រុមសិក្សាស្រាវជ្រាវមិនអាចសិក្សាលំអិតលើបរិមាណជាក់ស្តែងបានឡើយសំរាប់ការសិក្សានេះ។

ចំពោះកុមារនៅភូមិកិគួងក្រោម ឃុំតាវែងក្រោម ស្រុកតាវែង អាចចូលរៀននៅសាលាបឋមសិក្សានៅភូមិទំពួនរឿងធំបានជាធម្មតាដូចកាលរស់នៅភូមិចាស់ដែរ។ នេះដោយសារតែភូមិថ្មីដែលអ្នកភូមិផ្លាស់មករស់នៅនេះស្ថិត នៅតែប្រមាណ ៤០០ ម៉ែត្រពីទន្លេប៉ុណ្ណោះ។ ដូចនេះការផ្លាស់ប្តូរទីលំនៅថ្មីមិនបានកាត់ផ្តាច់ដំណើរការរៀនសូត្ររបស់០កុមារទាំងនេះឡើយ។

ចំពោះកុមារដែលផ្លាស់ប្តូរទីលំនៅចេញទៅតាមឪពុកម្តាយនៅស្រុកវើនសៃវិញបានទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីការផ្លាស់ប្តូរកន្លែងរស់នៅថ្មីនេះ ។ កុមារភាគច្រើនដែលកំពុងរស់នៅតំបន់ថ្មីមិនបានចូលរៀនឡើយ ដោយសារតែ ទីតាំងភូមិថ្មីទាំងនោះស្ថិតនៅឆ្ងាយពីសាលារៀន ហើយកុមារដែលមិនបានចូលរៀនទាំងនោះភាគច្រើនជាជនជាតិដើម ភាគតិច ប៉ុន្តែក្នុងនោះក៏មានកុមារជនជាតិឡាវខ្លះដែរ ។ ដោយយោងតាមស្ថិតិគ្រួសារតាមភូមិនិមួយៗ និងស្ថានភាព អប់រំនៅតាមតំបន់ទាំងនោះ ចំនួនកុមារដែលមិនបានចូលរៀននៅតំបន់ថ្មីនៅស្រុកវើនសៃមានប្រមាណ ២០៤ នាក់ ក្នុងនោះកុមារដែលកំពុងរស់នៅតំបន់អូរឆ្នាំងមានចំនួនច្រើនជាងគេ ។

## គ. ការប្រើប្រាស់ព្រៃឈើសំរាប់ចំការថ្មី



ការកាប់ព្រៃដើម្បីធ្វើចំការនៅតំបន់តាំងទីលំនៅថ្មី

ជាការពិតការរស់នៅតាមតំបន់ព្រៃភ្នំ គឺពឹងអាស្រ័យលើធនធានព្រៃឈើនៅតំបន់នោះដើម្បីចិញ្ចឹមជីវិត ។ ការផ្លាស់ទីលំនៅថ្មីទៅរស់នៅតាមតំបន់ព្រៃភ្នំជះឥទ្ធិពលយ៉ាងខ្លាំងដល់ធនធានធម្មជាតិនៅតំបន់នោះ ជាពិសេសព្រៃឈើ ។ ប្រជាជនដែលចាកចេញពីទន្លេសេសានទៅរស់នៅតំបន់ទាំងនោះពឹងផ្អែកទាំងស្រុងលើការ ធ្វើចំការសំរាប់ទ្រ- ទ្រង់ជីវភាពគ្រួសារ ។ ហើយអ្នកភូមិកាប់រានដីព្រៃដើម្បីដាំដំណាំស្រូវ និងបន្លែរួមផ្សំទៅតាមតំរូវការសំរាប់គ្រួសារនិមួយៗ ។

នេះជាការផ្លាស់ប្តូរប្រព័ន្ធចិញ្ចឹមជីវិតថ្មី ដោយផ្លាស់ប្តូរពីការពឹងអាស្រ័យលើទន្លេសេសានប្តូរមកការរស់នៅពឹងលើធនធានព្រៃឈើវិញ ។ ជាមធ្យមអ្នកភូមិ ០១ គ្រួសារ អាចធ្វើចំការចាប់ពី ២-៣ ហិចតា អាស្រ័យទៅតាមចំនួនសមាជិកគ្រួសារ និងកំលាំង ដែលអាចធ្វើទៅបាន ។ នេះបង្ហាញអោយឃើញថា ប្រជាជន ០១ គ្រួសារ ដែលផ្លាស់ទៅរស់នៅតាមតំបន់ភ្នំត្រូវកាប់រានដីព្រៃសំរាប់ធ្វើចំការ ចំនួន ២-៣ ហិចតាដែរ ។ ដោយយោងតាមទិន្នន័យប្រជាជនបោះបង់ទីលំនៅចេញពីទន្លេសេសាននេះអាចធ្វើការប៉ាន់ ស្មានថាព្រៃឈើដែលត្រូវបានអ្នកភូមិកាប់រានសំរាប់ធ្វើចំការមានទំហំប្រមាណ ១,៤០០ ហិចតា ។

*លោក **ទើ ថាម៉ិង** ជាជនជាតិគ្រឹងរស់នៅតំបន់ច្រប់ចាឡ ស្រុកវើនសៃ បាននិយាយថា "គ្រួសារខ្ញុំមានដីចំការ ៤ ហិចតា ហើយយើងដាំស្រូវ ល្ង និងដើមចន្ទីនៅក្នុងចំការនេះ ។"*

## ឃ. ខ្វះទឹកប្រើប្រាស់នៅរដូវប្រាំង

អ្នកភូមិដែលរស់នៅតំបន់ថ្មី តាមតំបន់ភ្នំ ពឹងអាស្រ័យលើទឹកច្រប់ ឬប្រភពទឹកពីព្រៃឈើ និងទឹកអូរជាដើមសំរាប់ប្រើប្រាស់ ក្នុងការរស់នៅដូចជា ងូត ធ្វើម្ហូប និងផឹក ។ ជាទូទៅអ្នកភូមិទៅរស់នៅតាមតំបន់ណាដែលមានអូរនៅ ជិតដើម្បីងាយស្រួល រកទឹកប្រើប្រាស់ក្នុងគ្រួសារ ប៉ុន្តែមានភូមិថ្មីមួយចំនួនក៏មិនមានអូរនៅជិតដែរ ។ ចំពោះភូមិដែល មិនមានអូរនៅជិតគេអាចប្រើប្រាស់ទឹកពីច្រប់ និងតំបន់ប្រភពទឹកពីព្រៃឈើផ្សេងៗ ។ នៅរដូវវស្សាអ្នកភូមិអាចត្រង ទឹកភ្លៀងទុកសំរាប់ប្រើប្រាស់មួយចំណែក រីឯមួយចំណែកទៀតអាចដងពីអូរ ច្រប់ និងអណ្តូងជីកដោយដៃ ។


ស្ត្រីជនជាតិចារាយដែលរស់នៅតំបន់ថ្មីកំពុងរងចាំដងទឹកច្រប់

ប៉ុន្តែអ្នក ភូមិខ្វះខាតទឹកប្រើប្រាស់យ៉ាងខ្លាំងនៅរដូវប្រាំង ហើយត្រូវចំណាយពេលវេលា និងកំលាំងច្រើនសំរាប់រកទឹកមកប្រើប្រាស់ក្នុងគ្រួសារ ។ នៅខែប្រាំង ទឹកច្រប់ ឬអណ្តូងដៃមិនសូវមានទឹកច្រើនទេ ម្យ៉ាងទៀតតំបន់ជិតភូមិអាចខ្សត់ទឹកដូចនេះអ្នកភូមិត្រូវទៅរកទឹកនៅឆ្ងាយ ពីភូមិបន្តិច ។ តាមប្រពៃណីជនជាតិដើមភាគតិច ស្ត្រីជាអ្នកទទួលបន្ទុកដងទឹក សំរាប់យកទៅប្រើប្រាស់ក្នុងគ្រួសារ ។

ក្រុមស្ត្រីនៅភូមិតាំងជិក ភូមិញ៉ាង ភូមិដាលប៉ក់ តាំង លោម និងតាំងម្លូ ឃុំញ៉ាង ស្រុកអណ្តូងមាសបាននិយាយថា អ្នកភូមិពិបាករកទឹកណាស់ជាពិសេសនៅរដូវប្រាំង ពីព្រោះកន្លែង ដែលអ្នកភូមិទៅដងទឹកនៅឆ្ងាយពីផ្ទះ ប្រមាណ ១-២ គីឡូម៉ែត្រ ហើយត្រូវរង់ចាំទឹកចេញទៀតផង ។ ដោយឡែកក្រុមស្ត្រីដែល កំពុងរស់នៅតំបន់ថ្មីនៅស្រុកវ៉ឺនសៃក៏បានប្រាប់ថា អ្នកភូមិពិបាក រកទឹកខ្លាំងនៅរដូវប្រាំង ពីព្រោះនៅតំបន់ថ្មីខ្សត់ទឹកនៅពេលអត់មានទឹកភ្លៀង ។ សំរាប់ប្រជាជននៅភូមិកិត្តួងក្រោម ស្រុកតាវែងវិញក៏មានការលំបាកក្នុងការរកទឹកប្រើប្រាស់នៅខែប្រាំងដែរ ប៉ុន្តែអ្នកភូមិមិនសូវលំបាកខ្លាំង ដូចអ្នកភូមិនៅតាមស្រុកផ្សេងៗ ទៀតឡើយ ។

## ង. មធ្យោបាយធ្វើដំណើរ

មធ្យោបាយធ្វើដំណើរគឺជាកត្តាដ៏សំខាន់សំរាប់ការទំនាក់ទំនង និងការចិញ្ចឹមជីវិតរបស់អ្នកភូមិក៏ដូចជាប្រជនជនរស់នៅតាមតំបន់ជនបទនានា ។ វាគួរអោយសោកស្តាយណាស់សំរាប់អ្នកភូមិដែលបានទៅរស់នៅតាមតំបន់ភ្នំថ្មីពី ព្រោះអ្នកភូមិបានជួបប្រទះនឹងការលំបាកយ៉ាងខ្លាំងក្នុងការធ្វើដំណើរ និងទំនាក់ទំនងព្រោះគ្មានផ្លូវលំសមរម្យសំរាប់អោយអ្នកភូមិធ្វើដំណើរ ហើយវាបានធ្វើអោយការទំនាក់ទំនងរបស់អ្នកភូមិជាមួយអ្នកខាងក្រៅមានការលំបាក ដូច ជាទៅផ្សារ ឬបុស្តិ៍សុខភាពជាដើម ។ ប៉ុន្តែសំរាប់អ្នកភូមិមួយចំនួនដែលកំពុងរស់នៅតាមតំបន់ថ្មីដែលមិនសូវជាឆ្ងាយ ពីទន្លេ និងភូមិចាស់មិនប្រឈមមុខនឹងការលំបាកក្នុងការធ្វើដំណើរឡើយ ។


ទិដ្ឋភាពផ្លូវ និងឧបសគ្គក្នុងការធ្វើដំណើរនៅ ភូមិតាំងម្លូ ឃុំញ៉ាង ស្រុកអណ្តូងមាស

ជនជាតិដើមភាគតិចចារាយចំនួន ៤ គ្រួសារ នៅភូមិភិ ស្រុកអូរយ៉ាដាវ ដែលបានផ្លាស់ទៅរស់នៅតំបន់ភ្នំឆ្ងាយពីភូមិចាស់មិនអាចធ្វើដំណើរមកទំនាក់ទំនងជាមួយអ្នកភូមិផ្សេងៗបានញឹកញាប់ឡើយ ។ អ្នកដែលរស់នៅក្នុងតំបន់ថ្មីធ្វើដំណើរទៅភូមិចាស់នៅពេលដែលត្រូវការទិញគ្រឿងហូប និងពេលមានធុរៈចាំបាច់ ហើយក្នុង ០១ ឆ្នាំ អាចចុះមកបានត្រឹមតែ ២-៣ ដង តែប៉ុណ្ណោះ។ នៅរដូវវស្សាអ្នកភូមិមិនអាចធ្វើដំណើរដោយថ្មើរជើងបានទេ ព្រោះផ្លូវ ដើរត្រូវស្មៅ និងស្បូវ ដុះលុបជិត ហើយមានចំងាយឆ្ងាយទៀតផង ( ប្រមាណ ៣០ គីឡូម៉ែត្រ ពីភូមិចាស់) ។

ប្រជាជនដែលបោះបង់ទីលំនៅចេញពីទន្លេសេសាននៅភូមិតាំងលោម ភូមិតាំងម្លូ ភូមិញ៉ាង ភូមិដាលប៉ក់ ភូមិ ដាលព្វ័រ និងភូមិតាំងជិក ឃុំញ៉ាង ស្រុកអណ្តូងមាស មានការលំបាកយ៉ាងខ្លាំងក្នុងការធ្វើដំណើរ និងទំនាក់ទំនងជា មួយអ្នកខាងក្រៅ។ ភូមិទាំងនេះស្ថិតនៅលើភ្នំដែលព័ទ្ធជុំវិញទៅដោយព្រៃឈើ ហើយនៅឆ្ងាយពីទីរួមឃុំ ។ អ្នកភូមិមិនទាន់មានផ្លូវលំសមរម្យសំរាប់ធ្វើដំណើរទៅមកនៅឡើយទេ គឺអ្នកភូមិធ្វើដំណើរចេញចូលកាត់តាមព្រៃ ។ នៅកំណាត់ផ្លូវខ្លះដូចជា ផ្លូវពីភូមិតាំងជិកទៅកាន់ភូមិដាលប៉ក់ និងដាលព្វ័រតម្រូវអោយអ្នកធ្វើដំណើរដោយអោនផងដោយសារតែមានព្រៃឈើ និងវល្លិ៍ជាច្រើនដុះគ្រប់ដណ្តប់លើដងផ្លូវ ។ អ្នកភូមិនៅទីនោះបាននិយាយថា ពួកគាត់មានការលំបាកខ្លាំងណាស់ពេលធ្វើដំណើរចេញទៅក្រៅភូមិម្តងៗ ហើយបើនៅរដូវវស្សាវិញផ្លូវកាន់តែយ៉ាប់ជាងរដូវប្រាំងទៅទៀត ។ សំរាប់អ្នកភូមិផ្សេងៗ ទៀត នៅឃុំញ៉ាងក៏មានការលំបាកក្នុងការធ្វើដំណើរផងដែរ ប៉ុន្តែការលំបាកនោះស្ថិតនៅក្នុងកំរិតមួយធូរស្រាលជាងបណ្តាភូមិខាងលើ ដោយសារភូមិខ្លះនៅជាប់ផ្លូវលំដែលអាចធ្វើដំណើរ ទៅមកបានធម្មតា ។

ប្រជាជនទាំង ៥ ភូមិ នៅស្រុកវើនសៃដែលកំពុងរស់នៅតំបន់ថ្មីក៏មានការលំបាកក្នុងការធ្វើដំណើរខ្លាំងណាស់ដែរ ។ អ្នកភូមិដែលជួបការលំបាកជាងគេក្នុងការធ្វើដំណើរក្នុងចំណោមភូមិទាំងនោះមាន ភូមិផាក់ណាម ភូមិឃួន និងភូមិប៉ាតឹង ។ ប្រជាជនក្នុងភូមិទាំង ៣ នេះកំពុងរស់នៅតំបន់ភ្នំដែលមានចំងាយប្រហែល ២០-៣០ គីឡូម៉ែត្រ ពីភូមិចាស់ ហើយមិនមានផ្លូវលំសមរម្យសំរាប់ការធ្វើដំណើរទេ ។ ទោះបីជាតំបន់ថ្មីដែលអ្នកភូមិមកពីភូមិកាចូនក្រោម និងភូមិបានប៉ុង កំពុងរស់នៅស្ថិតនៅជាប់ផ្លូវធំពីទីរួមខេត្តមកទីរួមស្រុកវើនសៃក៏ដោយ ក៏អ្នកភូមិនិយាយថា មានការលំបាកក្នុងការទំនាក់ទំនងជាមួយអ្នកខាងក្រៅភូមិដោយសារតែនៅឆ្ងាយពីគេ ។ ពួកគាត់បន្តថាពេលឈឺម្តងៗ យើងលំបាកណាស់ដោយសារតែនៅឆ្ងាយពីមណ្ឌលសុខភាពស្រុក ហើយកូនក៏មិនអាចចូលរៀនបានដែរដោយសារតែនៅ ឆ្ងាយពីសាលារៀន ។

វាជាការពិតណាស់ ការរស់នៅតាមតំបន់ថ្មីរបស់អ្នកភូមិទាំងនេះពិតជាអាចប្រឈមមុខនឹងបញ្ហាជាច្រើនទាក់ទងនឹងការធ្វើដំណើរ និងការទំនាក់ទំនងដែលជាផ្នែកដ៏សំខាន់នៅក្នុងដំណើរការចិញ្ចឹមជីវិតរបស់អ្នកភូមិ ហើយការអាក់ខាននៅក្នុងដំណើរការទំនាក់ទំនងធ្វើឱ្យអ្នកភូមិហាក់បីដូចជាកំពុងរស់នៅឯកឯងឆ្ងាយពីគេ ។ ម្យ៉ាងទៀត ដោយសារតែការរស់នៅដាច់ឆ្ងាយពីគេអាចធ្វើអោយអ្នកភូមិបាត់បង់ឱកាសទទួលបាននូវសេវាកម្មសាធារណៈផ្សេងៗ ។

## ៦. សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើ ក្រុមសិក្សាអាចធ្វើសេចក្តីសន្និដ្ឋានបានថាការផ្លាស់ទីលំនៅរបស់អ្នកភូមិតាមដងទន្លេសេសានទៅរស់នៅតំបន់ខ្ពង់រាប និងតំបន់ភ្នំខ្ពស់ៗឆ្ងាយពីទន្លេ គឺជាការទទួលរងនូវឥទ្ធិពលពីការប្រែប្រួលរបស់ទន្លេដែលបង្កឡើងដោយទំនប់វារីអគ្គិសនីនៅតំបន់ខ្សែទឹកខាងលើ ។

ឥទ្ធិពលទំនប់វារីអគ្គិសនីបានបង្កអោយទន្លេសេសានមានការប្រែប្រួលយ៉ាងខ្លាំង ហើយការប្រែប្រួលនេះបានធ្វើអោយប្រព័ន្ធចិញ្ចឹមជីវិតរបស់សហគមន៍ដែលកំពុងរស់នៅតាមដងទន្លេជួបប្រទះការលំបាកយ៉ាងខ្លាំងដែរ ។ ធនធានទន្លេយ៉ាងច្រើន ក្នុងនោះត្រីដែលធ្លាប់តែដើរតួនាទីយ៉ាងសំខាន់សំរាប់ការផ្គត់ផ្គង់ម្ហូបអាហារដល់អ្នកភូមិត្រូវបានថយចុះ និងបាត់បង់យ៉ាងច្រើន ។ ការបាត់បង់ធនធានទន្លេជាហេតុដ៏សំខាន់ដែលបណ្តាលឱ្យប្រជាជនដែលពឹងអាស្រ័យលើទន្លេជួបប្រទះនឹងបញ្ហាខ្វះស្បៀងអាហារ ។ ហើយសុខភាពរបស់ប្រជាជនទាំងនោះក៏ជួបបញ្ហាច្រើនផងដែរដែលបណ្តាលមកពីកត្តាម្ហូបអាហារ និងគុណភាពទន្លេ ។ លើសពីនេះទៅទៀត របបទឹកមិនទៀងទាត់របស់ទន្លេបានធ្វើឱ្យប្រជាជនមានការភ័យខ្លាចរៀងរាល់ថ្ងៃ ជាពិសេសនៅរដូវវស្សា ។

បញ្ហាខាងលើ គឺជាកត្តាដ៏សំខាន់បំផុតដែលធ្វើអោយប្រជាជនចំនួន **៣,៥៤៥** នាក់ នៅក្នុង **៧២២** គ្រួសារ សំរេចចិត្តចាកចេញពីទន្លេសេសានទៅរស់នៅតាមតំបន់ភ្នំ និងខ្ពង់រាបឆ្ងាយពីទន្លេទៅវិញ ។ ប្រជាជនទាំងនេះភាគច្រើន គឺជនជាតិដើមភាគតិចដែលធ្លាប់រស់នៅពឹងអាស្រ័យលើទន្លេសេសាននេះតាំងពីយូរយារណាស់មកហើយ ។ ការបាត់បង់ធនធានទន្លេ និងរបបទឹកឡើងចុះមិនទៀងទាត់ដូចជាទឹកជំនន់គឺជាកត្តាដ៏ចំបងដែលបណ្តាលអោយមាន ការផ្លាស់ទីលំនៅថ្មីនេះ ។

ការរស់នៅតំបន់ថ្មីអ្នកភូមិទាំងនេះអាចមានលក្ខណៈល្អប្រសើរផ្នែកស្បៀងអាហារបន្តិច ប៉ុន្តែក៏មានបញ្ហាជា ច្រើនទៀតដែលអាចកើតមានពីការតាំងទីលំនៅថ្មីនេះដូចជាការកាប់ព្រៃឈើថ្មីសំរាប់ធ្វើចំការ ការធ្វើដំណើរ និងកុមារ មិនបានទទួលការអប់រំជាដើម ។

បញ្ហាទាំងនេះពិតជាគួរអោយព្រួយបារម្ភខ្លាំងណាស់ ពីព្រោះមកដល់បច្ចុប្បន្ននេះយើងមិនទាន់មានយន្តការដោះស្រាយ និងការបង្ការនៅឡើយ ។ ដូច្នេះយើងខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលនៃប្រទេសកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសវៀតណាមមេត្តាជួយស្វែងរកយន្តការ និងដំណោះស្រាយដ៏មានប្រសិទ្ធភាពដើម្បីទប់ស្កាត់បុព្វហេតុដែលបង្ក អោយមានបញ្ហាទាំងនេះ ។ ការដោះស្រាយ និងទប់ស្កាត់បញ្ហាខាងលើនេះពិតជាការយកចិត្តទុកដាក់ និងទទួលខុសត្រូវយ៉ាងខ្លាំងចំពោះជនរងគ្រោះ ។

## ៧. អនុសាសន៍

ក្រុមសិក្សាស្រាវជ្រាវបានរកឃើញអនុសាសន៍មួយចំនួនដូចខាងក្រោម :

- ការសិក្សាជាក់លាក់បន្ថែមទៀតគួរតែធ្វើ ជាពិសេសទាក់ទងនឹងការអប់រំរបស់កុមារនៅភូមិ ឬតំបន់រស់នៅថ្មី ក្រោយពេលចាកចេញពីភូមិចាស់ បរិមាណជាក់ស្តែងនៃដីស្រែចំការដែលបាត់បង់ដោយសារការផ្លាស់ប្តូរទីលំនៅថ្មី ។
- ការសិក្សាអំពីផលប៉ះពាល់របស់ទំនប់មកលើសហគមន៍រងគ្រោះ និងទន្លេមួយចំនួនទៀតគួរតែធ្វើជាប្រចាំ និងដោយមានការចូលរួមពីសហគមន៍ ដូចជាទាក់ទងនឹងមុខរបរដាំដំណាំតាមច្រាំងទន្លេ ការបាត់បង់បន្លែព្រៃ និងបញ្ហាសុខភាពដែលបណ្តាលមកពីប្រើប្រាស់ទឹកទន្លេសេសានជាដើម ។
- គួរតែបង្កើនការចូលរួមពីសហគមន៍មូលដ្ឋានសំរាប់ការសិក្សាអំពីផលប៉ះពាល់របស់ទំនប់មកលើសហគមន៍ និងបរិស្ថាន ហើយប្រសិនបើអាច គឺសហគមន៍មូលដ្ឋានតែម្តងគួរតែអនុវត្តដោយខ្លួនឯង ។
- គួរតែបន្តការសិក្សាដោយសហគមន៍មូលដ្ឋានបែបនេះទៀត ហើយសមត្ថភាពក្រុមសិក្សាតាមសហគមន៍ គួរតែពង្រឹងបន្ថែមទៀតដើម្បីអោយពួកគេអាចធ្វើការសិក្សាបានល្អទៅថ្ងៃអនាគត ។
- រដ្ឋាភិបាលគួរតែបង្កើនការថែរក្សា និងយកចិត្តទុកដាក់ដល់ជនរងគ្រោះដែលកំពុងរស់នៅតំបន់ថ្មី ។

## ឯកសារភ្ជាប់បន្ថែម

១- ស្ថិតិប្រជាជនកំពុងរស់នៅតាមដងទន្លេសេសានជាក់ស្តែងនៅស្រុកអូរយ៉ាដាវ

| ល.រ | ឈ្មោះភូមិ | ឃុំ | ចំនួនគ្រួសារ | ចំនួនប្រជាជនរួម | ស្រី | ជនជាតិភាគច្រើន |
|---|---|---|---|---|---|---|
| ០១ | ផាដល | សេសាន | ៨៨ | ៤០៨ | ២០៣ | ចារាយ |
| ០២ | កាតាំង | សេសាន | ៤២ | ២២៥ | ១១៩ | ចារាយ |
| ០៣ | ភិ | សេសាន | ១០២ | ៤៣៩ | ២២១ | ចារាយ |
| **សរុប** | **៣ភូមិ** | **១ឃុំ** | **២៣២** | **១០៧២** | **៥៤៣** | **ចារាយ** |

២- ស្ថិតិប្រជាជនកំពុងរស់នៅតាមដងទន្លេសេសានជាក់ស្តែងនៅស្រុកអណ្តូងមាស

| ល.រ | ឈ្មោះភូមិ | ឃុំ | ចំនួនគ្រួសារ | ចំនួនប្រជាជនរួម | ស្រី | ជនជាតិភាគច្រើន |
|---|---|---|---|---|---|---|
| ០១ | កេត | ញ៉ាង | ២០ | ១០០ | ៤៩ | ចារាយ |
| ០២ | តាំងបខាំ | ញ៉ាង | ២០ | ៩៤ | ៤១ | ចារាយ |
| ០៣ | ដាលវែលលែង | ញ៉ាង | ២៦ | ១១១ | ៦៩ | ចារាយ |
| ០៤ | កាជូតទន្លេ | ញ៉ាង | ៤០ | ២១២ | ១១៨ | កាចក់ |
| ០៥ | កាណាតតូច | តាឡាវ | ២៥ | ១០៤ | ៦៤ | កាចក់ |
| ០៦ | តាឡាវ | តាឡាវ | ៧៩ | ៤៥៣ | ២៤៤ | ឡាវ |
| ០៧ | អ៊ិន | តាឡាវ | ៥៧ | ៣០៨ | ១៥៥ | កាចក់ |
| ០៨ | កាក់ | តាឡាវ | ៤៩ | ២៨២ | ១៤២ | កាចក់ |
| ០៩ | តាណង់ | តាឡាវ | ៤៣ | ២២៥ | ១០៦ | កាចក់ |
| **សរុប** | **៩ភូមិ** | **២ឃុំ** | **៣៥៩** | **១៨៨៩** | **៩៨៨** | |

៣- ស្ថិតិប្រជាជនកំពុងរស់នៅតាមដងទន្លេសេសានជាក់ស្តែងស្រុកតាវែង

| ល.រ | ឈ្មោះភូមិ | ឃុំ | ចំនួនគ្រួសារ | ចំនួនប្រជាជនរួម | ស្រី | ជនជាតិភាគច្រើន |
|---|---|---|---|---|---|---|
| ០១ | ចាន់ | តាវែងលើ | ៣៩ | ១៣១ | ៧៩ | គ្រឹង |
| ០២ | ជួយ | តាវែងលើ | ៧៧ | ៣៥០ | ១៧២ | គ្រឹង |
| ០៣ | តាបូក | តាវែងលើ | ៨៨ | ៤២៤ | ២៦១ | ព្រៅ |
| ០៤ | បង្អិត | តាវែងលើ | ៦៣ | ៣០៦ | ១៦១ | ព្រៅ |
| ០៥ | រវៀងរិញ | តាវែងលើ | ៤៩ | ២០២ | ១០២ | ព្រៅ |
| ០៦ | ភ្លីធំ | តាវែងលើ | ៣៩ | ១៥៩ | ៨៦ | ព្រៅ |
| ០៧ | កិគួងលើ | តាវែងលើ | ៤៦ | ២០៨ | ១១០ | ព្រៅ |
| ០៨ | សញ | តាវែងលើ | ៤២ | ១៧៦ | ៨៩ | ព្រៅ |
| ០៩ | ភ្លីតូច | តាវែងលើ | ៤៩ | ១៨៥ | ៨៥ | ព្រៅ |
| ១០ | តាវែង | តាវែងលើ | ២០៨ | ១០១១ | ៥១៧ | ព្រៅ |

## ឯកសារភ្ជាប់បន្ថែម

| | | | | | | |
|---|---|---|---|---|---|---|
| ១១ | ទំពួនរឹងធំ | តាវែងក្រោម | ៩៧ | ៤២៦ | ១៩៩ | ព្រៅ |
| ១២ | សៀងសាយ | តាវែងក្រោម | ៤៣ | ១៩១ | ១១០ | ព្រៅ |
| ១៣ | កោះប៉ង់ | តាវែងក្រោម | ១២ | ៥២ | ២៣ | ព្រៅ |
| ១៤ | ផាយ៉ាង | តាវែងក្រោម | ៥២ | ២២១ | ១០៧ | ព្រៅ |
| ១៥ | តាង៉ាច | តាវែងក្រោម | ២១ | ៩២ | ៥១ | ព្រៅ |
| ១៦ | ទំពួនរឹងតូច | តាវែងក្រោម | ៤៥ | ២០៤ | ៩៥ | ព្រៅ |
| ១៧ | វៀងចាន់ | តាវែងក្រោម | ២៩ | ១០៧ | ៦២ | ព្រៅ |
| ១៨ | ផាវ | តាវែងក្រោម | ១២៤ | ៥២៤ | ២៦៤ | ព្រៅ |
| ១៩ | ទុន | តាវែងក្រោម | ៦៣ | ២៨៣ | ១៤០ | ព្រៅ |
| **សរុប** | **១៩ភូមិ** | **២ឃុំ** | **១១៨៦** | **៥២៥២** | **២៧១៣** | |

៤- ស្ថិតិប្រជាជនកំពុងរស់នៅតាមដងទន្លេសេសានជាក់ស្តែងនៅស្រុកវឺនសៃ

| ល.រ | ឈ្មោះភូមិ | ឃុំ | ចំនួនគ្រួសារ | ចំនួនប្រជាជនរួម | ស្រី | ជនជាតិភាគច្រើន |
|---|---|---|---|---|---|---|
| ០១ | ហាតប៉ក់ | ហាតប៉ក់ | ១៤៥ | ៨៦៥ | ៤៥៦ | ឡាវ |
| ០២ | វឺនហយ | ហាតប៉ក់ | ៥៩ | ៣៣៥ | ១៦៩ | ឡាវ |
| ០៣ | លំប៉ាត់ | ហាតប៉ក់ | ១៦ | ៦៦ | ៣៧ | គ្រឹង |
| ០៤ | ប៉ាកកាឡាន់ | ប៉ាកកាឡាន់ | ១២៨ | ៦៥៤ | ៣២០ | ឡាវ |
| ០៥ | កំពុងចាម | ប៉ាកកាឡាន់ | ៩៧ | ៤១៦ | ២០៦ | ឡាវ |
| ០៦ | បានប៉ុង | បានប៉ុង | ១៣៣ | ៨៦២ | ៤៥១ | ឡាវ |
| ០៧ | បានហ្វាំង | បានប៉ុង | ២០៩ | ១៤៧២ | ៦១០ | ឡាវ |
| ០៨ | កោះពាក | កោះពាក | ១៧៨ | ៨៧៥ | ៥១៥ | កាចក |
| ០៩ | ផាកណាម | កោះពាក | ២២១ | ១៦៤ | ៤៣៩ | គ្រឹង |
| ១០ | ឃួន | កោះពាក | ១០៩ | ៤៨២ | ២៦១ | គ្រឹង |
| ១១ | ភ្នំកុកឡាវ | ភ្នំកុក | ៥៩ | ៣៨៣ | ១៦៤ | ឡាវ |
| ១២ | ភ្នំកុកព្រៅ | ភ្នំកុក | ៥៤ | ២៩៥ | ១៣៣ | ព្រៅ |
| ១៣ | ទៀមក្រោម | ភ្នំកុក | ៥៧ | ២៨៨ | ១៦៥ | លួន |
| ១៤ | កាចូនលើ | កាចូន | ៩១ | ៣៦២ | ១៩២ | ទំពួន |
| ១៥ | កាចូនក្រោម | កាចូន | ៧៥ | ៣៥៤ | ១៨៩ | ទំពួន |
| ១៦ | កាលឹម | កាចូន | ៦៤ | ២២៨ | ១០១ | គ្រឹង |

## ឯកសារភ្ជាប់បន្ថែម

| | | | | | | |
|---|---|---|---|---|---|---|
| ១៧ | ទៀមលើ | កាចូន | ៧០ | ២៩៥ | ១៤៦ | គ្រឹងលូន |
| ១៨ | ប៉ាហយ | កោះប៉ង់ | ៤៨ | ១៩១ | ៩២ | ព្រៅ |
| ១៩ | ប៉ាតិង | កោះប៉ង់ | ៤៧ | ១៣៤ | ៧៣ | ព្រៅ |
| ២០ | ឡាំអារ | កោះប៉ង់ | ៤៦ | ២៧៧ | ១៤២ | ព្រៅ |
| ២១ | វ៉ឺនសៃ | វ៉ឺនសៃ | ៦៣ | ៤៩០ | ២៩៧ | ឡាវ |
| ២២ | បាក់កែ | វ៉ឺនសៃ | ២០ | ១១៨ | ៦១ | ឡាវ |
| ២៣ | ថ្មីចិន | វ៉ឺនសៃ | ៤៨ | ២៣៨ | ១១២ | ចិន |
| ២៤ | កាឡាន់ញៃ | វ៉ឺនសៃ | ១៦៤ | ៩៩៩ | ៤៩៦ | ឡាវ |
| ២៥ | ភូមិថ្មី | វ៉ឺនសៃ | ២២ | ១៣០ | ៦៨ | ឡាវ |
| ២៦ | ឡាមើយទន្លេ | កុកឡាក់ | ២០ | ១២០ | ៦៨ | កាវែត |
| **សរុប** | **២៦ ភូមិ** | **៩ ឃុំ** | **២,២៤៧** | **១១,០៩៣** | **៥,៩២៣** | |

**សំគាល់ :** **ភូមិទាំងអស់ដែលបានចុះសិក្សា យើងប្រើទិន្នន័យថ្មីឆ្នាំ ២០០៦ ចំណែកឯភូមិផ្សេងទៀតយើងប្រើទិន្នន័យ ឆ្នាំ ២០០៥ ពីស្ថិតិឃុំ និងភូមិ (ស្ថិតិប្រជាជនឆ្នាំ ២០០៥ របស់មន្ទីរផែនការ ខេត្តរតនគិរី) ។**

# ABANDONED VILLAGES ALONG THE SESAN RIVER IN RATANAKIRI PROVINCE,

# NORTHEASTERN CAMBODIA









**A Community-Based Research Project**
**with**
**Technical Assistance by the 3S Rivers Protection Network (3SPN)**

**August 2007**

3 S Rivers Protection Network

Published by:
**3S Rivers Protection Network (3SPN)**
P.O. Box: 89007
Banlung Town, Ratanakiri Province
Cambodia
Tel: (855) 75 974 112
Email: sesan@camshin.net

This research was initiated by the local people living along the Sesan River in Ratanakiri province, northeastern Cambodia. The research was carried out by 17 local community researchers with technical assistance by the 3S Rivers Protection Network. Broederlinjk Delen has provided financial support to have the report published.

Suggested Citation:

3S Rivers Protection Network 2007. *Abandoned Villages along the Sesan River in Ratanakiri Province, Northeastern Cambodia.* 3S Rivers Protection Network. Banlung, Ratanakiri, Cambodia.

# Table of Content


Executive Summary ....................i
Acknowledgements ....................ii
1. Introduction ....................1
2. Goal and Specific Objectives of the Research ....................1
3. Study Area and Limitations ....................2
4. Research Methodology ....................3
5. Research Findings ....................5
5.1 Overview of the villages and people who have abandoned the Sesan River and resettled ....................5
5.2 Reasons why villages along the Sesan River are being abandoned ....................10
5.2.1 Frequent Floods ....................10
5.2.2 Fear that dam may break in future ....................11
5.2.3 Loss of Food Security ....................13
5.2.4 Requirement of New Chamkar and Land Encroachment Protection ....................14
5.3 Impacts of Resettlement in New Areas ....................14
5.3.1 Positive Impacts of the abandonment ....................14
A. Food Security ....................14
B. Income Generation ....................15
C. Health ....................16
D. Living without fear of the dam ....................16
5.3.2 Negative Impacts of the abandonment ....................16
A. Loss of Chamkars and Paddy Rice Fields ....................16
B. Education ....................17
C. Clearing of forests for new Chamkars ....................17
D. Water Shortages during the Dry Season ....................18
E. Transportation Obstacles ....................18
6. Conclusion ....................20
7. Recommendations ....................20

**Appendix**

Population statistics in Oyadao district along Sesan river ....................21
Ppulation statistics in Andong Meas district along Sesan river ....................21
Population statistics in Taveng district along Sesan river ....................21
Population statistics in Veun Sai district along Sesan river ....................22

# Executive Summary

Thousands of riparian villagers (who are mainly indigenous people) have been dependent on the resources of the Sesan River for many years. Yet the Sesan River can no longer be trusted by these people anymore. The reason for this is that the Sesan River has been seriously impacted by a hydropower dam located upstream of the river. In efforts to restore the Sesan River as well as the livelihoods of the people living along the river, the Sesan villagers have struggled to improve their socio-economic and environmental conditions and to protect their human rights.

One initiative by impacted communities along the Sesan River that has been implemented is a participatory community based study entitled "Abandoned Villages along the Sesan River in Ratanakiri Province." This study was written in order to contribute to protection the Sesan River and was conducted by communities living along the Sesan River. Technical assistance, including report writing, was provided to the researchers by the 3S Rivers Protection Network (3SPN). The research was conducted between May through October 2006, in order to collect information regarding the abandoned villages located along the Sesan River.

